ខុមហ្វ្រែល COMFREL

# របាយការណ៍ឃ្លាំមើលលទ្ធផល
# នៃការអនុវត្តន៍គោលនយោបាយ
# បង្កើនល្បឿនកែទម្រង់អភិបាលកិច្ច
# របស់រាជរដ្ឋាភិបាលនីតិកាលទី៦ ឆ្នាំទី២
# និងការវាយតម្លៃនៃការអនុវត្តគោលការណ៍អភិបាលកិច្ចល្អ
# នៅមូលដ្ឋានឃុំ/សង្កាត់




ខែមីនា ឆ្នាំ២០២១

# របាយការណ៍

# ស្តីពី

# ការឃ្លាំមើលលើលទ្ធផលនៃការអនុវត្តន៍គោលនយោបាយ បង្កើនល្បឿនកែទម្រង់អភិបាលកិច្ច

# របស់រាជរដ្ឋាភិបាលនីតិកាលទី៦ ឆ្នាំទី២

# និងការវាយតម្លៃនៃការអនុវត្តគោលការណ៍អភិបាលកិច្ចល្អ

# នៅមូលដ្ឋានឃុំ/សង្កាត់

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា
Committee for Free and Fair Elections in Cambodia
ខុមហ្វ្រែល COMFREL

**ទស្សនៈវិស័យ** ៖ សង្គមប្រជាធិបតេយ្យមួយ ដែលការបោះឆ្នោតប្រកបដោយលក្ខណៈប្រជាធិបតេយ្យ ត្រូវបានលើកកម្ពស់ និងមានគុណសម្បត្តិគ្រប់គ្រាន់ដើម្បីនាំប្រយោជន៍ដល់ប្រជាជនៗ
**Vision**: A democratic society where democratization in particular democratic elections are promoted and qualified to bring benefit to people.

ថ្ងៃពុធ ១០រោច ខែចេត្រ ឆ្នាំឆ្លូវ ទោស័ក, ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២១

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ការវាយតម្លៃនៃការអនុវត្តអភិបាលកិច្ចល្អនៅមូលដ្ឋានឃុំ/សង្កាត់

រាជរដ្ឋាភិបាលក្នុងនីតិកាលទី៦ បានកើតចេញពីលទ្ធផលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៨។ គិតត្រឹមខែសីហា ឆ្នាំ២០២០ រាជរដ្ឋាភិបាលនីតិកាលទី៦នេះ មានសមាជិកចំនួន ៤៧រូប ជាសមាជិកគណៈរដ្ឋមន្ត្រី។ មន្ត្រីជាន់ខ្ពស់យ៉ាងហោចណាស់ចំនួន ៩០១រូប ដែលក្នុងនោះជារដ្ឋលេខាធិការចំនួន ២៦០រូប អនុរដ្ឋលេខាធិការចំនួន ៤១៥ រូប រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ចំនួន ១៩រូប និងទីប្រឹក្សារដ្ឋាភិបាល ២០៧រូប។

សមាជិកឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ត្រូវបានបញ្ឈប់ ឬដកចេញពីតួនាទីដោយយល់ថាអ្នកទាំងនោះបានធ្វើកិច្ចការហួសព្រំដែនដែលមាន។ ឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់នេះ ត្រូវបានចាត់ទុកថា ជាយន្តការក្រៅសភាដែលទទួលធាតុចូលបន្ថែមពីគណបក្សនយោបាយ មិនមានឯករាជ្យពេញលេញក្នុងការបំពេញភារកិច្ចរបស់ខ្លួនដូចអ្នកតំណាងរាស្ត្រដែលប្រជាពលរដ្ឋបោះឆ្នោត និងផ្តល់អំណាចឱ្យនោះឡើយ។

ថវិកាចំណាយថ្នាក់ជាតិ នៃរាជរដ្ឋាភិបាលក្នុងឆ្នាំទី២ បានធ្លាក់ចុះក្នុងការអនុវត្តគោលនយោបាយរបស់ខ្លួន លើវិស័យសង្គម និងសេដ្ឋកិច្ច បើគិតជាភាគរយប្រៀបធៀបនឹងឆ្នាំ២០១៩។ ប៉ុន្តែផ្ទុយពីឆ្នាំមុនៗ រាជរដ្ឋាភិបាលបានគ្រោងថវិកាចំណាយមិនទាន់បែងចែក រហូតដល់ ២៧ភាគរយនៃថវិកាចំណាយថ្នាក់ជាតិសរុប ស្របពេលដែលកាលឆ្នាំ២០១៩ រដ្ឋាភិបាលបានគ្រោងខ្ទង់ចំណាយនេះត្រឹមតែ១៩ភាគរយតែប៉ុណ្ណោះ។

នៅថ្នាក់ក្រោមជាតិ ខុមហ្វ្រែលបានរៀបចំវេទិកាប្រជាពលរដ្ឋស្តីពីការផ្សព្វផ្សាយ និងវាយតម្លៃដំណើរការអភិបាលកិច្ចល្អនៅមូលដ្ឋានឃុំ/សង្កាត់។ វេទិកានេះ មានគោលបំណងសំខាន់ៗ ៣ចំណុចគឺ ទី១ ចែករំលែកចំណេះដឹងពីគោលការអភិបាលកិច្ចល្អ ទី២ ផ្តល់ការជជែកពិភាក្សារវាងប្រជាពលរដ្ឋជាមួយសមាជិកក្រុមប្រឹក្សាឃុំសង្កាត់លើបញ្ហាដែលកើតមានដើម្បីរកដំណោះស្រាយ និងទី៣ ផ្តល់ឱកាសឱ្យមានការចូលរួមវាយតម្លៃពីប្រជាពលរដ្ឋលើការអនុវត្តគោលការណ៍អភិបាលកិច្ចល្អនៅឃុំសង្កាត់។ វេទិកាប្រជាពលរដ្ឋនេះ បានរៀបចំឡើងចំនួន០៦ ក្នុងមូលដ្ឋានឃុំ/សង្កាត់ចំនួន០៦ នៃខេត្តចំនួន០៦។ វេទិកានេះ មានប្រជាពលរដ្ឋក្នុងឃុំ/សង្កាត់សរុបចំនួនប្រមាណ ១៨០នាក់បានចូលរួម។ មតិក្រោយវេទិកានៃការចូលរួមរបស់ប្រជាពលរដ្ឋ និងសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ បានសម្តែងការអបអរសាទរ និងយល់ថា វេទិកានេះ បានផ្តល់សារៈសំខាន់ក្នុងការយល់ដឹងរបស់ពួកគេ រួមទាំងជម្រុញឱ្យមានការចូលរួមតាមដាននូវដំណើរការអភិវឌ្ឍន៍ឃុំសង្កាត់ទៀតផង។

តាមរយៈវេទិកាដែលមានការជជែកគ្នារវាងប្រជាពលរដ្ឋជាមួយក្រុមប្រឹក្សាឃុំសង្កាត់ ខុមហ្វ្រែលបានកំណត់បញ្ហាប្រឈមធំៗ ចំនួន០៤ ដែលបានលើកឡើង និងត្រូវការស្វែងរកដំណោះស្រាយពីក្រុមប្រឹក្សាឃុំសង្កាត់ មានដូចជា៖

- សុំឱ្យមានការចូលរួមពីប្រជាពលរដ្ឋ ជាពិសេសយុវជនក្នុងដំណើរការកសាងផែនការអភិវឌ្ឍនានា
- ការរក្សាសណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាពចរាចរណ៍ និងសុវត្ថិភាពនៅមូលដ្ឋានភូមិ/ឃុំ
- ស្នើឱ្យ អាជ្ញាធរយកចិត្តទុកដាក់លើបញ្ហា ក្នុងមូលដ្ឋានដូចជា សាលារៀន ផ្សារ និងសិទ្ធិរបស់កុមារ
- បង្កើនការយកចិត្តទុកដាក់លើភាពអសកម្មរបស់អាជ្ញាធរមូលដ្ឋានក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋ

ទាក់ទង និងការដោះស្រាយបញ្ហាខាងលើ ក្រុមប្រឹក្សាឃុំសង្កាត់បានស្នើសុំការសហការពីប្រជាពលរដ្ឋដើម្បីដោះស្រាយបញ្ហាសិទ្ធិកុមារ និងសាលារៀន និងបញ្ហាភូមិឃុំមានសុវត្ថិភាពនៅក្នុងឃុំ/សង្កាត់។ ការស្នើសុំបង្កើតផ្សារ ឬហេដ្ឋារចនាសម្ព័នផ្លូវថ្នល់ជាដើមត្រូវសិក្សា និងពិចារណាបញ្ចូលក្នុងផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់ប្រចាំឆ្នាំ។

ប្រជាពលរដ្ឋដែលចូលរួមក្នុងវេទិកាបានផ្តល់ពិន្ទុវាយតម្លៃលើការពេញចិត្ត ឬមិនពេញចិត្តរបស់ខ្លួន ចំពោះការអនុវត្តគោលការណ៍អភិបាលកិច្ចល្អ នៃចំណុចទាំង៨ មានដូចជា៖ គោលការណ៍ការចូលរួមរបស់ប្រជាពលរដ្ឋ នីតិរដ្ឋ នៅក្នុងឃុំសង្កាត់ តម្លាភាព ការព្រមព្រៀងឯកភាពគ្នា សមធម៌ ប្រសិទ្ធភាពខ្ពស់ គណនេយ្យភាព និងគោលការណ៍ការឆ្លើយតប។ ការអនុវត្តគោលការណ៍ទាំងនោះ ដើម្បីអភិវឌ្ឍន៍មូលដ្ឋានឃុំសង្កាត់ត្រូវបានប្រជាពលរដ្ឋដែលបានចូលរួមវាយតម្លៃលើ ការពេញចិត្តចំនួន ៨៩ ភាគរយ (ពេញចិត្តទាំងស្រុង ៣០ភាគរយ ចំនួន ៣៤ភាគរយពេញចិត្តច្រើន និងប្រមាណ ២៥ភាគរយទៀតមានការពេញចិត្តមធ្យម)។ ជាមួយគ្នានេះ ប្រជាពលរដ្ឋមួយចំនួន ក៏បានសម្តែងការមិនពេញចិត្ត ឬមិនពេញចិត្តខ្លះមានចំនួនប្រមាណ ១១ភាគរយ។

បើពិនិត្យមើលពិន្ទុជាមធ្យម ដែលប្រជាពលរដ្ឋបានដាក់ចំពោះលទ្ធផលនៃការអនុវត្តគោលការណ៍ទាំងនេះវិញ គឺឱ្យតម្លៃស្ថិតក្នុងចំណុចលេខ ៣.៨ នៃពិន្ទុ៥។ ដូចនេះ តាមរយៈការវាយតម្លៃនេះ អាជ្ញាធរឃុំសង្កាត់ ត្រូវតែបន្តការខិតខំប្រឹងប្រែងក្នុងការអនុវត្តគោលការណ៍ទាំង ៨ចំណុចនៃអភិបាលកិច្ចល្អមូលដ្ឋានឃុំសង្កាត់ប្រកបដោយប្រសិទ្ធិភាពខ្ពស់ ដើម្បីបន្តទទួលបានការពេញចិត្តពីប្រជាពលរដ្ឋ និងការគាំទ្របន្ថែមទៀត។ របាយការណ៍លម្អិតមានផ្សាយក្នុងគេហទំព័រផ្លូវការរបស់ខុមហ្វ្រែល ៖ www.comfrel.org។

***សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖***


| | | |
|---|---|---|
| ១. លោក គន សាវ៉ាង្ស | អ្នកសម្របសម្រួលផ្នែកអង្កេត និងតស៊ូមតិ | ០១១ ៨៨៤ ៨៤០ |
| ២. លោក សៀន ប៊ុនរិទ្ធ | មន្ត្រីផ្នែកអង្កេត | ០១១ ៥៣ ៥៣ ៥៤ |

**Vision**: A democratic society where democratization in particular democratic elections are promoted and qualified to bring benefit to people.

**Phnom Penh, April 07th, 2021**

# Press Release

## Assessment on Fulfillment of Good Governance at Local Communes

The sixth legislature Royal Government of Cambodia (RGC) was formed from the results of the National Assembly election in 2018. By August 2020, the RGC has 47 members of it cabinet. Further there are at least 901 high ranking officials of the RGC, including 260 Secretaries of State, 415 Undersecretaries of State, 19 Ministers of Prime Ministers delegation, and 207 government advisers.

The Supreme Advisory Council which newly established to promote further inputs from political parties instead of the National Assembly, is not able to perform independently as the parliamentarians have done. Some of them were reported to misuse of their power and they were fired.

To compare to the percentage in 2019, the government has allocated less national budget to social and economic sectors. In contrast from previous times, RGC allocated 27% of its budget which has not demonstrated yet it expenditure while in 2019 there was only 19%.

At local community, COMFREL organized a People Forum on Dissemination and Evaluation of Good Governance Process at local Commune/Sangkat. The forum is aimed to 1) promote and raise awareness among the people about good governance principles, 2) to make possibility for people and their authority to discuss and address their common issues and 3) to provide opportunity to have a score card on principles implementation. The People's Forums have been organized in 6 communes/Sangkats of 6 provinces with 180 people of almost villages from those communes/Sangkats. In the forum, they could learn more about the principles of good governance at the commune/Sangkat. Following the forum, People and Commune / Sangkat Councilors applauded the importance of their further understanding and; urging more engagement in monitoring the Commune/Sangkat development process.

In the forum, there was a discussion between the people and the Commune/Sangkat Councilors. COMFREL consequently identified four major challenges/ issues that were raised and needed to be addressed for them as following:

- More engagement of people participation, especially of young generation in the process of development planning of communes/Sangkats
- Maintaining public order, traffic safety and safety accordingly to the policy of safe commune/village
- Asking the authorities to pay more attention to local issues such as schools, markets and children's rights
- Motivating the authority to minimize the passive response/interventions in providing services to the people

Promptly response to people's issue, The Commune/Sangkat Councilors also requested the cooperation from people to address the issue raised above of children's rights and schools and the issue of safe villages and communes in the commune/Sangkat. While for some proposals in accordance with development, they needed

further considerations and discussions. establishing markets or road infrastructure must be studied and considered in the annual commune/Sangkat development plan.

People who participated in the forum also conducted the scorecard on their satisfaction with the implementation of the eight principles of good governance, such as: the principle of citizen participation, the rule of law in the commune, transparency, consensus, equitability, high efficiency, accountability and response principles. The implementation of those principles for the development their commune/Sangkat was assessed by the people who participated. Consequently, about 89% of them are satisfied with the outcome of implementation (30% were completely satisfied; about 34% were highly/strongly satisfied; and 25% moderately satisfied). At the same time, the number of people who have expressed dissatisfaction and less satisfaction is about 11%.

For an average score, it is 3.8 out of 5 points. Therefore, according to the result, the commune/Sangkat authorities must continue their efforts to implement the eight principles of good governance in the commune /Sangkat with higher efficiency in order to get more satisfaction from the people. A full report is available at COMFEL's website: www.comfrel .org

**For more information:**

1. Mr. Korn Savang Coordinator of Monitoring and Advocacy Unit 011 884 840
2. Mr. Sean Bunrith Monitoring Officer 011 53 53 53

# មាតិកា

I. ខ្លឹមសារសង្ខេប ........................................ 3

II. សេចក្តីផ្តើម ........................................ 3

III. វិធីសាស្ត្រ និងដែនកំណត់នៃរបាយការណ៍ ........................................ 4

IV. សមាជិករាជរដ្ឋាភិបាល និងការបង្កើតស្ថាប័នក្រោមចំណុះថ្មី ........................................ 5

1. សមាជិករាជរដ្ឋាភិបាល ........................................ 5

2. យន្តការទទួលធាតុចូល៖ ការបង្កើតស្ថាប័នក្រោមចំណុះថ្មីរបស់រាជរដ្ឋាភិបាល ........................................ 8

V. ថវិកាថ្នាក់ជាតិគ្រោងចំណាយឆ្នាំ ២០២០ ........................................ 11

VI. គោលនយោបាយរាជរដ្ឋាភិបាលនីតិកាលទី៦៖ ការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ច ........................................ 12

VII. ការអនុវត្តគោលនយោបាយ "បង្កើនល្បឿនកែទម្រង់អភិបាលកិច្ច"៖ លទ្ធផល និងបញ្ហាប្រឈម ..14

VIII. ការផ្តល់ពិន្ទុលើការអនុវត្តគោលការណ៍អភិបាលកិច្ចល្អនៅមូលដ្ឋានឃុំ/សង្កាត់ ........................................ 23

ក. ការផ្តល់ចំណេះដឹងដល់ប្រជាពលរដ្ឋពីគោលការណ៍អភិបាលកិច្ចល្អ ........................................ 24

ខ. ការពិភាក្សារវាងប្រជាពលរដ្ឋ និងក្រុមប្រឹក្សាឃុំសង្កាត់ ........................................ 25

គ. ការវាយតម្លៃដំណើរការអភិបាលកិច្ចល្អដោយផ្តល់ពិន្ទុ ........................................ 26

IX. សេចក្តីសន្និដ្ឋាន ........................................ 28

X. ផ្នែកឧបសម្ព័ន ........................................ 29

លក្ខខណ្ឌនៃការវាយតម្លៃ និងផ្តល់ពិន្ទុ ........................................ 29

ព័ត៌មាននៃអ្នកចូលរួមផ្តល់ពិន្ទុ ........................................ 29

លទ្ធផលវាយតម្លៃតាមឃុំ/សង្កាត់ ........................................ 29

បញ្ជីសំណួរសម្រាប់ប្រជាពលរដ្ឋវាយតម្លៃ ........................................ 34

គោលការណ៍ទាំង០៨ នៃអភិបាលកិច្ចល្អមូលដ្ឋាន ........................................ 38

រូបភាពសកម្មភាពវេទិកាប្រជាពលរដ្ឋនៅឃុំ/សង្កាត់ ........................................ 39

## I. ខ្លឹមសារសង្ខេប

រាជរដ្ឋាភិបាលក្នុងនីតិកាលទី៦ នៃរដ្ឋសភានេះ បានកើតចេញពីលទ្ធផលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ២០១៨ ។ គិតត្រឹមឆ្នាំ២០២០ រាជរដ្ឋាភិបាលនីតិកាលទី៦នេះ មានសមាជិកចំនួន ៤៧ រូប ប៉ុន្តែមានមន្ត្រីជាន់ខ្ពស់យ៉ាងហោចណាស់ចំនួន ៩០១ រូប (ដែលជារដ្ឋលេខាធិការ ២៦០ រូប អនុរដ្ឋលេខាធិការ៤១៥ រូប រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ១៩ រូប និងទីប្រឹក្សារដ្ឋាភិបាល ២០៧ រូប)។ រដ្ឋាភិបាលមានគោលនយោបាយធ្វើកំណែទម្រង់អភិបាលកិច្ចល្អក្នុងស្ថាប័នសាធារណៈ ការកើនឡើងនៃចំនួនមន្ត្រីជាន់ខ្ពស់ គឺមិនអាចបង្ហាញអំពីប្រសិទ្ធភាពនៃកំណែទម្រង់បានឡើយ។ ឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ ដែលបានបង្កើតថ្មី និងត្រូវបានចាត់ទុកថាជាយន្តការក្រៅសភាដែលទទួលធាតុចូលបន្ថែមពីគណបក្សនយោបាយ មិនមានឯករាជ្យពេញលេញការបំពេញភារកិច្ចរបស់ខ្លួនឡើយ។

នៅក្នុងគោលនយោបាយការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ច និងកិច្ចការងារជាអាទិភាពរបស់រាជរដ្ឋាភិបាលដែលបានចែង ឬសន្យា តាមរយៈយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ មិនបានកំណត់នូវសូចនាករច្បាស់លាស់ដើម្បីវាស់វែងពីសមិទ្ធផលនោះទេ។

រាជរដ្ឋាភិបាល ក្នុងឆ្នាំទី២នៃការអនុវត្តគោលនយោនបាយរបស់ខ្លួន បានគ្រោងចំណាយថវិកាថ្នាក់ជាតិ ប្រមាណ ៧.៧៧៣,៩៦ លានដុល្លារអាមេរិក។ ថវិកាចំណាយថ្នាក់ជាតិត្រូវចំណាយលើវិស័យសង្គម និងសេដ្ឋកិច្ចបានធ្លាក់ចុះ បើប្រៀបធៀបនឹងឆ្នាំ២០១៩។ ប៉ុន្តែផ្ទុយពីឆ្នាំមុនៗ រាជរដ្ឋាភិបាលបានគ្រោងថវិកាចំណាយមិនទាន់បែងចែករហូតដល់២៧%នៃថវិកាចំណាយថ្នាក់ជាតិសរុប ស្របពេលដែលកាលឆ្នាំ២០១៩រដ្ឋាភិបាលបានគ្រោងខ្ទង់ចំណាយនេះត្រឹមតែ១៩%តែប៉ុណ្ណោះ។

ដោយឡែកសម្រាប់ការអនុវត្តគោលការណ៍អភិបាលកិច្ចល្អដើម្បីអភិវឌ្ឍន៍មូលដ្ឋានឃុំ/សង្កាត់ត្រូវបានប្រជាពលរដ្ឋដែលបានចូលរួមវាយតម្លៃចំនួន ៣៤% ពេញចិត្តច្រើន ប្រមាណ១១%មិនពេញចិត្ត និងពេញចិត្តខ្លះ និងប្រមាណ២៤% ទៀតមានការពេញចិត្តមធ្យម ចំពោះលទ្ធផលនៃការអនុវត្តគោលការណ៍នៅមូលដ្ឋានឃុំ/សង្កាត់។ បើពិនិត្យមើលពិន្ទុជាមធ្យមដែលប្រជាពលរដ្ឋបានដាក់ចំពោះលទ្ធផលនៃការអនុវត្តគោលការណ៍ទាំងនេះវិញគឺ ៣.៨នៃ ពិន្ទុ៥។

## II. សេចក្តីផ្តើម

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) បានអនុវត្តគម្រោងឃ្លាំមើលការអនុវត្តការសន្យារបស់រាជរដ្ឋាភិបាល តាំងពីនីតិកាលទី ៣ នៃរដ្ឋសភា និងនីតិកាលបន្តបន្ទាប់ រហូតដល់នីតិកាលទី៦ នៃរដ្ឋសភា។ របាយការណ៍ឃ្លាំមើលការអនុវត្តន៍ការសន្យារបស់រាជរដ្ឋាភិ បាល ត្រូវបានបង្កើតឡើងជារៀងរាល់ឆ្នាំ ដើម្បីវាយតម្លៃចំពោះការអនុវត្តន៍ការសន្យា ផ្អែកតាមគោលនយោ

បាយរបស់ខ្លួនដែលបានដាក់ចេញនៅដើមនីតិកាលនីមួយៗ។ រាជរដ្ឋាភិបាលនីតិកាលទី៦ នេះ ត្រូវបានរដ្ឋសភាដែលមានតំណាងរាស្ត្រមកពីគណបក្សតែមួយ គឺគណបក្សប្រជាជនកម្ពុជា បោះឆ្នោតផ្តល់សេចក្តីទុកចិត្តថ្ងៃទី៦ ខែកញ្ញា ឆ្នាំ ២០១៨[1] ។

ក្នុងនីតិកាលទី៦ ទាំងរដ្ឋាភិបាល និងរដ្ឋសភា ស្ថិតនៅក្រោមការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជាតែមួយគត់ ខុសពីអាណត្តិមុនៗដែលរដ្ឋាភិបាលដឹកនាំដោយគណបក្សកាន់អំណាច ចំណែកឯគណបក្សប្រឆាំងមានតំណាងរាស្ត្រនៅក្នុងរដ្ឋសភា។

ក្រោយពីចូលកាន់តំណែង នាយករដ្ឋមន្ត្រីបានប្រកាសដាក់ចេញជាផ្លូវការ ក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រីលើកទី១ នូវការដាក់ចេញការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ ដែលមានមូលដ្ឋានពីកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៦ និងជាមូលដ្ឋានក្នុងការរៀបចំ និងបង្កើតផែនយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩-២០២៣។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ គឺដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព៖ កសាងមូលដ្ឋានឆ្ពោះទៅចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០។

ដើម្បីចូលរួមបង្កើនតម្លាភាព និង~~ការ~~ទទួលខុសត្រូវរបស់រាជរដ្ឋាភិបាលចំពោះការអនុវត្តនូវគោលនយោបាយរបស់ខ្លួន សម្រាប់ឆ្នាំទី២នៃការអនុវត្តគោលនយោបាយ អង្គការខុមហ្វ្រែលបាន និងកំពុងសង្កេតលើការអនុវត្តគោលនយោបាយស្នូលនៃយុទ្ធសាស្ត្រចតុកោណ គឺការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ច។ ក្នុងការសង្កេតអំពីការអនុវត្តគោនយោបាយស្នូលនៃយុទ្ធសាស្ត្រ ខុមហ្វ្រែលបានសង្កេត និងតាមដានការអនុវត្តគោលនយោបាយនេះនៅថ្នាក់ជាតិ និងរៀបចំការវាយតម្លៃដោយប្រជាពលរដ្ឋលើការអនុវត្តគោលការណ៍អភិបាលកិច្ចល្អនៅមូលដ្ឋានឃុំ/សង្កាត់ផងដែរ។

របាយការណ៍ឃ្លាំមើលលើលទ្ធផលការអនុវត្តន៍គោលនយោបាយបង្កើនល្បឿនកែទម្រង់អភិបាលកិច្ច និងការវាយតម្លៃនិងការវាយតម្លៃនៃការអនុវត្តគោលការណ៍អភិបាលកិច្ចល្អនៅមូលដ្ឋានឃុំ/សង្កាត់ មានពីរផ្នែកធំៗគឺ ទី១ការសង្កេត និងតាមដានការអនុវត្តគោលនយោបាយនេះនៅថ្នាក់ជាតិ ដោយផ្អែកលើសិក្សា និងវាយតម្លៃតាមរយៈឯកសារដែលមានស្រាប់ និងទី២លទ្ធផលនៃការវាយតម្លៃដំណើរការអភិបាលកិច្ចនៅឃុំ/សង្កាត់មួយចំនួនតាមរយៈការរៀបចំវេទិកាប្រជាពលរដ្ឋ។

## III. វិធីសាស្ត្រ និងដែនកំណត់នៃរបាយការណ៍

របាយការណ៍នេះកើតចេញពីការវិភាគលើទិន្នន័យ និងព័ត៌មានដែលមានស្រាប់មកពីប្រព័ន្ធផ្សព្វផ្សាយរបាយការណ៍បឋមរបស់អង្គការជាតិ និងអន្តរជាតិ សារព័ត៌មានជាតិ និងអន្តរជាតិ ព្រមទាំងស្ថាប័នជាតិ និងអន្តរជាតិផ្សេងៗ ដែលពាក់ព័ន្ធនឹងគោលនយោបាយបង្កើនល្បឿនកែទម្រង់អភិបាលកិច្ច របស់រាជរដ្ឋាភិបាលអាណត្តិទី៦។ មួយផ្នែកទៀតនៃរបាយការណ៍នេះគឺកើតចេញពីរៀបចំវេទិកាប្រជាពលរដ្ឋស្តីពីការ

[1] Also see: Xinhua: Cambodian PM Changes date of forming new gov't after winning election, August 8th 2018; http://www.xinhuanet.com/english/2018-08/08/c_137375680.htm

ផ្សព្វផ្សាយ និងវាយតម្លៃដំណើរការអភិបាលកិច្ចល្អនៅមូលដ្ឋានឃុំ/សង្កាត់។ វេទិកាប្រជាពលរដ្ឋខាងលើបានរៀបចំឡើងចំនួន០៦ នៃមូលដ្ឋានឃុំ/សង្កាត់ចំនួន០៦ នៃខេត្តចំនួន០៦[2]។ ក្នុងវេទិកាប្រជាពលរដ្ឋខាងលើប្រជាពលរដ្ឋនៃឃុំ/សង្កាត់ចំនួនប្រមាណ ១៨០នាក់ បានចូលរួមឈ្វេងយល់បន្ថែមអំពីគោលការណ៍អភិបាលកិច្ចល្អនៅមូលដ្ឋានឃុំ/សង្កាត់ ការលើកបញ្ហាប្រឈម និងសំណូមពរដល់ក្រុមប្រសក្សាឃុំសង្កាត់ជួយដោះស្រាយ និងបានចូលរួមវាយតម្លៃលើដំណើរការអភិបាលកិច្ចល្អនៅមូលដ្ឋានឃុំ/សង្កាត់របស់ពួកគាត់ផ្ទាល់ផងដែរ។

ក្នុងការចងក្រងរបាយការណ៍នេះ ខុមហ្វ្រែលក៏មានបញ្ហាប្រឈម ផងដែរ ក្នុងការប្រមូលព័ត៌មានសម្រាប់ធ្វើការវិភាគ ដូចជា ការខ្វះខាតព័ត៌មានសម្រាប់ការវិភាគការអនុវត្តគោលនយោបាយ បង្កើនល្បឿនកែទម្រង់អភិបាលកិច្ច ដែលបណ្តាលមកពីការមិនអាចទទួលបានជាសាធារណៈនូវទិន្នន័យ ព័ត៌មាន ឯកសារ និងរបាយការណ៍ចាំបាច់ ពីស្ថាប័នរបស់រដ្ឋរួមទាំងសិទ្ធិទទួលបានព័ត៌មានប្រកបដោយតម្លាភាពពីស្ថាប័នរដ្ឋនៅតែជាឧបសគ្គសម្រាប់ការធ្វើរបាយការណ៍នេះ។

ក្រៅពីការបញ្ហាប្រឈមក្នុងការប្រមូលព័ត៌មាន ក៏ជួបបញ្ហាប្រឈមពីការរីករាលដាលឆ្លងនៃជម្ងឺ កូវីដ-១៩ផងដែរ។ ជាពិសេសការរៀបចំវេទិកាប្រជាពលរដ្ឋនៅថ្នាក់ឃុំ/សង្កាត់ត្រូវបានលើកពេល រួមទាំងការព្រួយបារម្ភចំពោះការឆ្លងរីករាលដាល ជាមួយការចូលរួមរបស់ប្រជាពលរដ្ឋ។ ទោះបីជាយ៉ាងណា គម្រោងនេះត្រូវបានអនុវត្តបានតាមផែនការ ដោយគោរព និងអនុវត្តតាមវិធានការសុខាភិបាល និងបន្តសម្របសម្រួលជាមួយអាជ្ញាធរពាក់ព័ន្ធផងដែរ។

# IV. សមាជិករាជរដ្ឋាភិបាល និងការបង្កើតស្ថាប័នក្រោមចំណុះថ្មី

## 1. សមាជិករាជរដ្ឋាភិបាល

រាជរដ្ឋាភិបាលនីតិកាលទី ៦ ដឹកនាំដោយ គណបក្សប្រជាជនកម្ពុជាមានក្រសួងចំនួន ២៨[3] និងមានលេខាធិការដ្ឋានចំនួន ១ នៅពេលចាប់ផ្តើមនីតិកាល។ ហើយនៅពេលចាប់ផ្តើមអាណត្តិរបស់ខ្លួន រាជរដ្ឋាភិបាលនេះមានសមាជិកចំនួន ៤៦ រូប នៃតួនាទីចំនួន ៥៧ (នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ១០ ទេសរដ្ឋមន្ត្រី ១៧ រដ្ឋមន្ត្រី ២៩)។ ហើយរាជរដ្ឋាភិបាលមានមន្ត្រីជាន់ខ្ពស់យ៉ាងហោចណាស់ចំនួន ៨៥៨ រូប ដែលជារដ្ឋលេខាធិការ ២៤១ រូប អនុរដ្ឋលេខាធិការ ៣៩១ រូប រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ១៩ រូប និងទីប្រឹក្សារដ្ឋាភិបាល ២០៧ រូប។

| ប្រភេទ | នីតិកាលទី៤ (ចំនួនតួនាទី) | នីតិកាលទី៥ (ចំនួនតួនាទី) | នីតិកាលទី៦ (ចំនួនតួនាទី) ឆ្នាំទី១ | នីតិកាលទី៦ (ចំនួនតួនាទី) ឆ្នាំទី២ |
|---|---|---|---|---|
| ➢ នាយករដ្ឋមន្ត្រី | 01 (ស្រី 0នាក់) | 01 (ស្រី 0 នាក់) | 01 (ស្រី 0នាក់) | 01(ស្រី 0នាក់) |

[3] ព្រះរាជក្រឹត្យលេខ០៩១៨/៩២៥, នរោត្តម សីហមុនី, ០៦ កញ្ញា ២០១៨

| | | | | |
|---|---|---|---|---|
| ➢ ឧបនាយករដ្ឋមន្ត្រី | 09 (ស្រី 01នាក់) | 09 (ស្រី 01 នាក់) | 10 (ស្រី 01 នាក់) | 10(ស្រី 01 នាក់) |
| ➢ ទេសរដ្ឋមន្ត្រី | 16 (ស្រី 0នាក់) | 15 (ស្រី 0 នាក់) | 17 (ស្រី 0នាក់) | 18(ស្រី 0នាក់) |
| ➢ រដ្ឋមន្ត្រី | 26 (ស្រី 02នាក់) | 28 (ស្រី 03 នាក់) | 29 (ស្រី 03នាក់) | 29(ស្រី 03នាក់) |
| ➢ រដ្ឋមន្ត្រីអមនាយករដ្ឋមន្ត្រី | 08 (ស្រី 0នាក់ ) | 14 (ស្រី 0 នាក់) | 19 (ស្រី 0នាក់) | 19(ស្រី 0នាក់) |
| ➢ រដ្ឋលេខាធិការ | 206 (ស្រី 15នាក់) | 187(ស្រី 38 នាក់) | 241 (ស្រី 37នាក់) | 260(ស្រី 37នាក់) |
| ➢ អនុរដ្ឋលេខាធិការ | | | 391 (ស្រី 58នាក់) | 415(ស្រី 58នាក់) |
| ➢ ទីប្រឹក្សារាជរដ្ឋាភិបាល | | | 207 (ស្រី17នាក់) | 207(ស្រី17នាក់) |

ក្នុងឆ្នាំទី២នៃនីតិកាលទី៦នេះ ចំនួនរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការនៃក្រសួងនានារបស់រាជរដ្ឋាភិបាលបានបន្តកើនឡើង។ រដ្ឋលេខាធិការកើនចំនួន ០៩រូប និងអនុរដ្ឋលេខាធិការកើនចំនួន ២៤រូប យោងតាមរាជកិច្ចដែលបានចេញផ្សាយត្រឹមខែសីហាឆ្នាំ២០២០។ ការកើនឡើងនៃចំនួនរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការដែលជាក្រុមមន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាល ក្រោយពេលដែលតួនាទីទាំងពីរមិនត្រូវបានចាត់ទុកសមាជិកគណៈរដ្ឋមន្ត្រី និងមិនមានការទទួលខុសត្រូវចំពោះរដ្ឋសភាឡើយ។ យោងតាមទិន្នន័យខាងលើចំនួនរដ្ឋលេខាធិការមានចំនួនប្រមាណ១៨៧រូប[4] នៅនីតិកាលទី៥ ហើយចំនួននេះបានកើនឡើងដល់ប្រមាណ២៦០រូប (កើនឡើង២៨%)គិតត្រឹមឆ្នាំទី២នៃនីតិកាលទី៦ ដោយឡែករវាងឆ្នាំទី១ និងឆ្នាំទី២ចំនួននេះបានកើនឡើងប្រមាណ៧%ផងដែរ។ អ្វីដែលគួរឲ្យកត់សម្គាល់ នៅពេលដែលនីតិវិធីតែងតាំងរដ្ឋលេខាធិការ មិនត្រូវឲ្យមានការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តពីរដ្ឋសភា ចំនួនរដ្ឋលេខាធិកាអាចនឹងកើនឡើងក្រោមហេតុផលដូចគ្នានឹងការតែងតាំងតួនាទីអនុរដ្ឋលេខាធិការ ដោយសារតែគ្មានបទបញ្ញត្តិកំណត់ពីចំនួនរដ្ឋាលេខាធិការ ចំនួនអនុរដ្ឋលេខាធិការនៃបណ្តាក្រសួងនានា។

សម្រាប់សមាជិករាជរដ្ឋាភិបាល (គណៈរដ្ឋមន្ត្រី) បើប្រៀបធៀបជាមួយរយៈពេលដើមនីតិកាលទី ៥ ចំនួនសមាជិកគណៈរដ្ឋមន្ត្រីមានចំនួនថយចុះយ៉ាងខ្លាំងពី ២៤៤ រូប មកត្រឹម ៨៦រូប។ ហើយគិតដល់ឆ្នាំទី២នៃនីតិកាលទី៦នេះចំនួនគណៈរដ្ឋមន្ត្រីកើនដល់ចំនួន៨៧រូប[5]។ ការធ្លាក់ចុះចំនួនសមាជិករាជរដ្ឋាភិបាលបណ្តាលមកពីការធ្វើវិសោធនកម្ម មាត្រា ១១៨[6] នៃរដ្ឋធម្មនុញ្ញ និង មាត្រា ៨[7] នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដោយកែប្រែសមាសភាពសមាជិករដ្ឋាភិបាលមានដូចជា នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី។ ដោយឡែក រដ្ឋលេខាធិការមិនត្រូវបានកំណត់ជាសមាភាពរដ្ឋាភិបាលឡើយ។ ការដកចេញនូវតួនាទីរដ្ឋលេខាធិការពីសមាជិករាជរដ្ឋាភិបាល នៅតែមិនទាន់ជានាបាននូវការធ្លាក់ចុះចំនួនមន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាលនោះទេ ស្របពេលដែលត្រូវបានគេរិះគន់ផងដែរថា នៅ

[4] រដ្ឋលេខាធិការជាសមាជិកគណៈរដ្ឋមន្ត្រី

[5] បន្ថែមឯកឧត្តម ពេជ្រ ប៊ុនធិន ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកម្ម ពិសេស

[66] Cambodia Constitution, Article 118 states: The Council of Ministers is the Royal Government of Cambodia. The Council of Ministers shall be led by one Prime Minister assisted by Deputy Prime Ministers, and by State Ministers, Ministers as members.

[7] សមាសភាពនៃរាជរដ្ឋាភិបាលមាន នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី។

កម្ពុជា កំពុងមានកំណើនកើនឡើងយ៉ាងច្រើនរហូតដល់ធ្វើឲ្យមាននូវអតិផរណាតួនាទីឯកឧត្តម[8] នៅពេលដែលមន្ត្រីរដ្ឋាភិបាលកាន់តែច្រើនទទួលបានការតំឡើងឋានៈជាឯកឧត្តម ឬលោកជំទាវ។

ការធ្វើវិសោធកម្មនេះ បណ្តាលឲ្យមានការកែប្រែនីតិវិធីនៃការតែងតាំងរដ្ឋលេខាធិការនៃក្រសួងនិងស្ថាប័នរដ្ឋាភិបាល ដោយអនុញ្ញាតឲ្យតួនាទីរដ្ឋលេខាធិកាត្រូវបានតែងតាំងតាមសំណើររបស់នាយករដ្ឋមន្ត្រីទៅព្រះមហាក្សត្រ និងមិនតម្រូវឲ្យបោះឆ្នោតផ្តល់សេចក្តីទុកចិត្តពីរដ្ឋសភានោះទេ។ ដូចនេះ រដ្ឋលេខាធិការនឹងមិនមានកាតួកិច្ចទទួលខុសត្រូវ ចំពោះរដ្ឋសភាដែលស្ថាប័ននីតិបញ្ញត្តិដែលកើតចេញពីការបោះឆ្នោតដោយប្រជាពលរដ្ឋ។ ជាទូទៅរដ្ឋលេខាធិការត្រូវបានទទួលប្រតិភូកម្មទាំងសមត្ថកិច្ច និងហត្ថលេខាពីរដ្ឋមន្ត្រីនៃក្រសួងរបស់ខ្លួនផ្ទាល់ ដើម្បីចាត់ចែងការងារផ្សេងៗជំនួសឲ្យរដ្ឋមន្ត្រី។ នៅពេលដែលរដ្ឋលេខាធិការដែលមិនមានទំនួលខុសត្រូវចំពោះរដ្ឋសភាអនុវត្តតួនាទី ឬចាត់ចែងការងារក្នុងនាមរដ្ឋមន្ត្រីដែលតម្រូវឲ្យមានទំនួលខុសត្រូវចំពោះរដ្ឋសភា វាពិតជាមិនស្របតាម ឬបង្កើតការសង្ស័យលើការរក្សាបាននូវតាមគោលការណ៍ការទទួលខុសត្រូវ ឬគណនេយ្យភាពក្នុងប្រព័ន្ធដឹកនាំរដ្ឋ។

យើងអាចសន្និដ្ឋានបានថា បើទោះបីជាចំនួនសមាជិកនៃរាជរដ្ឋាភិបាលនីតិកាលទី៦ បានថយយ៉ាងច្រើន ចំនួនមន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាលនៅតែបន្តកើនឡើងដដែល។ ការបន្តកើនឡើងនៃចំនួនមន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាលនីតិកាលទី៦ ក៏ជាមូលហេតុមួយនៃការបន្ថែមបន្ទុកចំណាយថវិកាជាតិប្រចាំឆ្នាំផងដែរ។ តាមច្បាប់ថវិកាជាតិសម្រាប់ការគ្រប់គ្រង រាជរដ្ឋាភិបាលគ្រោងថវិកាចំនួន ២,១ ពាន់លានដុល្លារអាមេរិកសម្រាប់ប្រាក់បៀវត្សរ៍មន្ត្រីរាជការ ក្នុងឆ្នាំ ២០២០។[9] រាជរដ្ឋាភិបាលមានគោលនយោបាយធ្វើកំណែទម្រង់អភិបាលកិច្ចល្អក្នុងស្ថាប័នសាធារណៈ ការកើនឡើងនៃចំនួនមន្ត្រីជាន់ខ្ពស់ គឺមិនអាចបង្ហាញអំពីប្រសិទ្ធភាពនៃកំណែទម្រង់បានឡើយ ស្របពេលដែលមានមតិរិះគន់លើកឡើងថា «មេដឹកនាំជំនាន់ថ្មីនៃវិស័យសាធារណៈនៅកម្ពុជា យ៉ាងហោចណាស់ ត្រូវមានផ្នត់គំនិតបែបកំណែទម្រង់ លើកស្ទួយការបង្កើតថ្មី និងទទួលយកនូវការផ្លាស់ប្តូរ។ របៀបដឹកនាំកន្លងមកដែលពឹងផ្អែកបុគ្គលនិយម និងទឹកប្រាក់នឹងមិនអាចអនុវត្តបានទៀតឡើយ»[10]។

ការបន្តកើនឡើងនូវចំនួនមន្ត្រីរាជការទាំងក្នុងក្រសួងស៊ីវិល និងការបង្កើនឋានៈនៅក្នុងកងកម្លាំងប្រដាប់អាវុធបានចោទជាសំណួរជាច្រើនទៅលើប្រសិទ្ធភាពនិងប្រសិទ្ធផល នៃដំណើរប្រត្តិបត្តិការនៃប្រព័ន្ធ

---

[8] Khmer Times: Leading reforms in Cambodia’s government, January 17th, 2020, https://www.khmertimeskh.com/680458/leading-reforms-in-government/

[9] Khmer Times: National Budget 2020 Approved, By Chea Vannak, November 27th , 2019; https://www.khmertimeskh.com/664298/national-budget-for-2020-approved/

[10]Khmer Times: Leading reforms in Cambodia’s government, January 17th, 2020; https://www.khmertimeskh.com/680458/leading-reforms-in-government/

គ្រប់គ្រងរដ្ឋ។ បញ្ហានេះវាកាន់តែមានភាពស្មុគស្មាញថែមទៀតនៅពេលដែលក្រុមអ្នកនយោបាយបន្តការដាក់បញ្ចូលសមាសភាពថ្មី(ឈាមថ្មី) ដែលភាគច្រើនសុទ្ធសឹងជាសាច់ញាតិ និងខ្សែស្រឡាយអ្នកដឹកនាំសំខាន់នៅក្នុងជួររាជរដ្ឋាភិបាល។ ការចំណាយច្រើនទៅលើបៀវត្សមន្ត្រីរាជាការក៏ជាបន្ទុកមួយទៀតដែលរដ្ឋត្រូវទទួលខុសត្រូវជាពិសេសនៅក្នុងអំឡុងមានវិបត្តិកូវីត១៩ ដែលយើងសង្កេតឃើញថារដ្ឋាភិបាលហាក់ដូចជាមានថវិកាជាតិតិចតួចស្តួចស្តើងណាស់ សំរាប់ជួយដល់ពលរដ្ឋដែលកំពុងទទួលរងផលប៉ះពាល់ដោយសារកូវីត។[11]

គួរកត់សម្គាល់នោះ គឺចំនួនស្ត្រីក្នុងសមាសភាពគណរដ្ឋមន្ត្រី និងមន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាលបានកើនឡើងក្នុងអំឡុងពេលនៃពីរនីតិកាលចុងក្រោយនេះ។ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី បានលើកឡើងថា «រដ្ឋមន្ត្រីជាស្ត្រីបានកើនឡើងពី សូន្យ ដល់ចំនួន០៣ រដ្ឋលេខាធិការជាស្ត្រីកើនដល់ចំនួន៥៣ នៅត្រឹមឆ្នាំ២០១៩ ចំណែកអនុរដ្ឋលេខាធិការជាស្ត្រីបានកើនលឡើងពីចំនួន០២រូប ដល់៧០រូបក្នុងរយៈពេលដូចគ្នា។[12]

## 2. យន្តការទទួលឆាគុចូលៈ ការបង្កើតស្ថាប័នក្រោមចំណុះថ្មីរបស់រាជរដ្ឋាភិបាល

លទ្ធផលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ២០១៨ បានធ្វើឲ្យកម្ពុជាមានរដ្ឋសភាឯកបក្សដោយសារតំណាងរាស្ត្រទាំង ១២៥ រូបមកពីគណបក្សប្រជាជនកម្ពុជាតែមួយគត់។ ដំណើរការរដ្ឋដែលអំណាចនីតិបញ្ញតិទាំងមូលលត្រូវផ្តល់ឲ្យគណបក្សកាន់អំណាច ដែលកំពុងដឹកនាំអំណាចនីតិប្រតិបត្តិត្រូវទទួលបានការរិះគន់ពីសហគមន៍អន្តរជាតិ និងនាំឲ្យបាត់បង់តុល្យភាពអំណាចរវាងស្ថាប័ននីតិបញ្ញតិ និងស្ថាប័ននីតិប្រតិបត្តិ។ នេះនឹងបង្កើតឲ្យមានការសង្ស័យអំពីតម្លាភាព និងគណនេយ្យភាពក្នុងការប្រើប្រាស់អំណាចសាធារណៈ។

នៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ ២០១៨ តាមរយៈការស្នើរបស់លោកនាយរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនីតិកាលទី៦ ព្រះមហាក្សត្រកម្ពុជា បានចេញព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់។ ការបង្កើតស្ថាប័នថ្មីនេះមានគោលបំណងលើកស្ទួយរបបនយោបាយសេរីពហុបក្សនៅកម្ពុជា យោងតាមមាត្រា ១ នៃព្រះរាជក្រឹត្យ។ គណបក្សនយោបាយចំនួន ២០ ដែលបានចូលរួមបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ២០១៨ ត្រូវបានបើកឲ្យមានឱកាសក្លាយជាប្រតិភូក្នុងឧត្តមក្រុមប្រឹក្សានេះ។ គណបក្សនយោបាយចំនួន ១៦ រួមទាំងគណបក្សប្រជាជនកម្ពុជា ក្នុងចំណោមគណបក្សនយោបាយចំនួន ២០ ដែលបានចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតឆ្នាំ ២០១៨ បានចូលរួម និងក្លាយជា

[11] ផ្អែកលើការសិក្សារបស់អ្នកសិក្សាស្រាវជ្រាវការអភិវឌ្ឍន៍សង្គម បណ្ឌិត មាស នី

[12] Phnom Penh Post: Calls for more women in leadership positions, by Niem Chheng, 12 Mach 2020; ; https://www.phnompenhpost.com/national/calls-more-women-leadership-positions?

ប្រតិភូគណបក្សក្នុងឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្ដល់យោបល់នេះ[13]។ ប្រតិភូដែលបានចូលរួមក្នុងឧត្តមក្រុមប្រឹក្សានេះត្រូវបានផ្ដល់ឋានៈស្មើទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី ហើយមានភារកិច្ចចំបង ដូចជា ការផ្ដួចផ្ដើម គំនិត ឬផ្ដល់យោបល់លើការរៀបចំគោលនយោបាយ ឬសេចក្ដីព្រាងច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាល និងការតាមដានការអនុវត្តច្បាប់ និងគោលនយោបាយរបស់រដ្ឋាភិបាលទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ យន្តការថ្មីនេះត្រូវបានគេវាយតម្លៃថា ជាយន្តការក្រៅសភាដែលទទួលធាតុចូលបន្ថែមពីគណបក្សនយោបាយ នៅពេលសភាមានតំណាងរាស្ត្រមកពីគណបក្សតែមួយ។

លោកនាយរដ្ឋមន្ត្រី ហ៊ុន សែន ថ្លែងនៅក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រីនៅថ្ងៃទី ៧ ខែមិថុនា ឆ្នាំ ២០១៩ ថា «នឹងមិនមានទៀតឡើយ ឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្ដល់យោបល់ នៅអាណត្តិក្រោយ។ លោក ផៃ ស៊ីផាន អ្នកនាំពាក្យរដ្ឋាភិបាលកម្ពុជា បានពន្យល់បន្ថែមថា មូលហេតុចំបងមួយដែលជំរុញឲ្យប្រមុខរដ្ឋាភិបាលកម្ពុជាសម្រេចចិត្តបែបនេះគឺដោយសារតែកន្លងមក សមាជិកឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្ដល់យោបល់មួយចំនួន ហាក់បានដើរហួសពីតួនាទីរបស់ខ្លួន។[14]

ការបង្កើតស្ថាប័នឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្ដល់យោបល់ មិនស្ថិតនៅក្រោមបទប្បញ្ញត្តិរដ្ឋធម្មនុញ្ញដូចចការជាការបង្កើតស្ថាប័នសភាជាតិឡើយ។ ម្យ៉ាងវិញទៀត បើទោះបីជាគោលបំណងក្នុងការបង្កើតស្ថាប័ននេះដើម្បីលើកស្ទួយ និងបង្កើនប្រសិទ្ធិភាពរបបនយោបាយសេរីពហុបក្សក្នុងដំណើរការរដ្ឋ តួនាទី និងការទទួលខុសត្រូវរបស់ឧត្តមក្រុមប្រឹក្សា និងសមាជិករបស់ខ្លួនមិនអាចទទួលបានឧត្តមភាពដូចរដ្ឋសភា និងសមាជិករដ្ឋសភាឡើយ ។

ជាការកត់សម្គាល់ នៅក្នុងឆ្នាំ២០២០នេះ សមាជិកនៃឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្ដល់យោបល់មួយចំនួន ត្រូវបានបញ្ឈប់មុខតំណែង តាមការស្នើថ្វាយរបស់ប្រមុខស្ថាប័ននីតិប្រតិបត្តិទៅព្រះមហាក្សត្រ។ សមាជិកម្នាក់នៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្ដល់យោបល់ គឺលោក សុខសុវណ្ណ វឌ្ឍនាសាប៊ុង ត្រូវបានបញ្ចប់ពីមុខតំណែងនៅថ្ងៃច័ន្ទទី៤ ខែឧសភានេះ ដោយមិនដឹងពីមូលហេតុពិតប្រាកដ បើយោងតាមព្រះរាជក្រឹត្យមួយលេខ០៥២០/៤៩៧ ចុះហត្ថលេខាដោយលោក សាយ ឈុំ ដែលបំពេញតួនាទីជាប្រមុខរដ្ឋស្ដីទី ជំនួសព្រះមហាក្សត្រដែលបានយាងទៅប្រទេសចិន។ លោក សុខសុវណ្ណ វឌ្ឍនាសាប៊ុង បានថ្លែងថា «លោកមិនបានដឹងអំពីមូលហេតុដែលលោក ហ៊ុន សែន បានស្នើឱ្យដកតំណែងលោកពីសមាជិកឧត្តមក្រុមប្រឹក្សា និងពិគ្រោះយោបល់នេះទេ ហើយមានតែលោក ហ៊ុន សែន ប៉ុណ្ណោះដែលអាចប្រាប់ពីមូលហេតុនេះបាន»[15]។ ការដកដំណែងនេះ ត្រូវបានសង្កេតឃើញថា កើតឡើងបន្ទាប់ពីលោកចុះទៅសិក្សាស្រាវជ្រាវអំពីវិវាទដីធ្លី

---

[13] Cambodia Daily: Cambodia Forms Supreme Council for Consultation and Recommendations, by Xinhua Net, September 7th, 2018; https://english.cambodiadaily.com/news/cambodia-forms-supreme-council-for-consultations-recommendations-140114/

[14] http://www.rfi.fr/km/cambodia/hun-sen-with-new-law-in-gov-07-06-2019

[15] https://www.postkhmer

មួយកន្លែងនៅស្រុកព្រៃនប់ខេត្តព្រះសីហនុ ហើយបានកើតមានបញ្ហាប្រទាំងប្រទើសជាមួយមន្ត្រីនៅខេត្តនោះ។

នៅចុងឆ្នាំ២០២០នេះដែរ លោក ចាន់ យ៉េត ប្រធានគណបក្ស នគរប្រជាធិបតេយ្យ ដែលជាសមាជិកឧត្តមក្រុមប្រក្សា ពិគ្រោះ និងផ្តល់យោបល់ មានឋានៈស្មើ ទេសរដ្ឋមន្ត្រីម្នាក់ទៀត ត្រូវបានព្រះករុណា ព្រះបាទ សម្តេចព្រះ បរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា បានចេញព្រះរាជក្រឹត្យបញ្ចប់មុខតំណែង នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២០។ ប្រធានគណបក្សរូបនេះ ត្រូវបានគេដឹងថា បានជាប់ពាក់ព័ន្ធទំនាស់ដីធ្លីនៅខេត្តបន្ទាយមានជ័យ។[16]

ការដកចេញ ឬបណ្តេញចេញនូវសមាជិកក្រុមប្រឹក្សាពិគ្រោះយោបល់ជាបន្តបន្ទាប់នាឆ្នាំកន្លងទៅនេះ វាបានចោទជាសំណួរសំខាន់មួយទៅលើអនាគតនៃស្ថាប័នមួយនេះ ទាំងតួនាទីនិងវត្តមាននៅក្នុងស្ថាប័នរដ្ឋ ខណៈដែលមានការព្រមានជាបន្តបន្ទាប់ពីសំណាក់លោកនាយករដ្ឋមន្ត្រីនោះថា ស្ថាប័ន្តមួយនេះអាចនិងត្រូវលែងអោយមាននៅអាណត្តិក្រោយៗទៀត។ ការបណ្តេញចេញដោយសារតែមូលហេតុនៃការចូលទៅរុករកឬសគល់នៃបញ្ហាដីធ្លីនោះដោយសមាជិកខ្លះនោះ ក៏នឹងបណ្តាលអោយមានការរួញរាដល់សមាជិកដទៃទៀតក្នុងការចូលរួមបំពេញកតព្វកិច្ចអោយបានពេកដៃពេញជើងផងដែរ។[17]

ជាការពិត ការបណ្តេញចេញនេះ បានបង្ហាញពីឧត្តមភាព និងអំណាចដែលស្ថិតនៅក្រោមគណបក្សកាន់អំណាច ដែលស្ថាប័ននេះវាគ្រាន់តែជាការសម្រុះសម្រួលផ្នែកនយោបាយតែប៉ុណ្ណោះ និងមិនត្រូវបានចែងនៅក្នុងច្បាប់ សេរីភាពក្នុងការអនុវត្តតួនាទីដូចតំណាងរាស្ត្រដែលប្រជាពលរដ្ឋជាអ្នកបោះឆ្នោតជូននោះឡើយ។ ជាងនេះទៀត វាបានបង្ហាញដល់សមាជិកនៃស្ថាប័នឧត្តមក្រុមប្រឹក្សា និងពិគ្រោះយោបល់ នូវដែនកំណត់នៃតួនាទីដោយកំណត់ព្រំដែននៃការអនុវត្ត។

[16] https://dap-news.com/national/2020/12/09/104250/

[17] អ្នកសិក្សាស្រាវជ្រាវការអភិវឌ្ឍន៍សង្គម បណ្ឌិត មាស នី

## v. ថវិកាថ្នាក់ជាតិគ្រោងចំណាយឆ្នាំ ២០២០




រាជរដ្ឋាភិបាល នៃរដ្ឋសភានីតិកាលទី៦ ដើម្បីអនុវត្តគោលនយោបាយរបស់ខ្លួន ក្នុងឆ្នាំទី២ បានគ្រោងចំណាយថវិកាថ្នាក់ជាតិ ប្រមាណ ៧.៧៧៣,៩៦ លានដុល្លារអាមេរិក(ប្រាំពីរពាន់ប្រាំពីររយចិតសិបបី និង ប្រាំបួនសែនប្រាំមួយម៉ឺន)។ ថវិកាចំណាយថ្នាក់ជាតិត្រូវចំណាយលើវិស័យសង្គមកិច្ចប្រមាណ២៥% ដែលបានធ្លាក់ចុះពី២៨%កាលពីឆ្នាំ២០១៩ ហើយថវិកាចំណាយលើវិស័យសេដ្ឋកិច្ចក៏បានធ្លាក់ចុះផងដែរ ពោលធ្លាក់ចុះពីប្រមាណ២៥%នៅឆ្នាំ២០១៩មកត្រឹម២៣%នៅឆ្នាំ២០២០នេះ។

| វិស័យថវិកាចំណាយ | ជាលានដុល្លា (USD) និងការប្រែប្រួល | | | | | | | | | កំណើនថវិកាប្រចាំឆ្នាំ ជាលានដុល្លា (USD) | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | $/% | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 | ប្រែប្រួល | 2014-15 | 2015-16 | 2016-17 | 2017-18 | 2018-19 | 2019-20 |
| រដ្ឋបាលទូទៅ | $ | 280.31 | 420.27 | 427.60 | 539.16 | 613.25 | 615.89 | 627.96 | | | | | | | |
| | % | 8.20 | 11.18 | 9.79 | 10.68 | 10.47 | 9.56 | 8.08 | | 139.96 | 7.33 | 111.56 | 74.092 | 2.6336 | 12.071 |
| ការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ | $ | 468.17 | 610.27 | 711.05 | 860.38 | 1001.42 | 1106.29 | 1197.95 | | | | | | | |
| | % | 13.80 | 16.24 | 16.29 | 17.05 | 17.10 | 17.18 | 15.41 | | 142.1 | 100.78 | 149.33 | 141.04 | 104.87 | 91.667 |
| សង្គមកិច្ច | $ | 791.47 | 1045.66 | 1209.66 | 1439.02 | 1753.52 | 1812.35 | 1967.58 | | | | | | | |
| | % | 23.30 | 27.82 | 27.71 | 28.51 | 29.94 | 28.14 | 25.31 | | 254.19 | 164 | 229.36 | 314.5 | 58.83 | 155.23 |
| សេដ្ឋកិច្ច | $ | 302.90 | 1073.78 | 1288.97 | 1349.16 | 1416.52 | 1655.11 | 1832.33 | | | | | | | |
| | % | 8.90 | 28.57 | 29.53 | 26.73 | 24.18 | 25.70 | 23.57 | | 770.88 | 215.19 | 60.19 | 67.363 | 238.59 | 177.21 |
| ចំណាយមិនទាន់បែងចែក | $ | 1556.04 | 608.82 | 728.35 | 858.90 | 1072.36 | 1251.61 | 2148.14 | | | | | | | |
| | % | 45.80 | 16.20 | 16.68 | 17.02 | 18.31 | 19.43 | 27.63 | | -947.22 | 119.53 | 130.55 | 213.46 | 179.26 | 896.53 |
| ចំណាយសរុបរួម | $ | 3398.90 | 3758.81 | 4365.62 | 5046.61 | 5857.07 | 6441.26 | 7773.96 | | 359.91 | 606.81 | 680.99 | 810.46 | 584.18 | 1332.7 |

ផ្ទុយពីឆ្នាំមុនៗ អ្វីដែលគួរឲ្យកត់សម្គាល់នោះ រាជរដ្ឋាភិបាលបានគ្រោងថវិកាចំណាយមិនទាន់បែងចែករហូតដល់២៧%នៃថវិកាចំណាយថ្នាក់ជាតិសរុប ស្របពេលដែលកាលឆ្នាំ២០១៩រដ្ឋាភិបាលបានគ្រោងខ្ទង់ចំណាយនេះត្រឹមតែ១៩%តែប៉ុណ្ណោះ។ ខ្ទង់ចំណាយមិនទាន់បែងចែកត្រូវកត់សម្គាល់ថាមិនលើសពី ២០%នៃថវិកាគ្រោងចំណាយប្រចាំឆ្នាំនីមួយៗ ក្នុងរយៈពេល០៥ឆ្នាំចុងក្រោយនេះ។ ខ្ទង់ចំណាយមិនទាន់បែងចែកបានធ្លាក់ចុះពី ៤៥% ក្នុងឆ្នាំ ២០១៤ ដល់១៩% ក្នុងឆ្នាំ ២០១៩ ហើយបែរជាបានកើនឡើងដល់

២៧%    ក្នុងឆ្នាំ២០២០វិញ។ការផ្ទុះរីករាលដាលនៃជម្ងឺកូវីត១៩នេះបានបណ្តាលអោយមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កំណើនលូតលាស់នៃសេដ្ឋកិច្ចជាតិផងដែរ។ ការព្យាករណ៍ របស់ធនាការពិភពលោកដែលចេញផ្សាយកាលពីដើមឆ្នាំ២០២០    បានបង្ហាញថាសេដ្ឋកិច្ចកម្ពុជាអាចនិងធ្លាក់ចុះពីជាង៧%នៅមុនកូវីតរហូតដល់ដក២%ឬទាបជាងនេះប្រសិនបើ  ជម្ងឺកូជាកូវីតនេះនៅបន្តរាតត្បាតនៅក្នុងប្រទេសកម្ពុជាហួសពីរយៈពេល៦ខែ។ វិស័យសរសរស្តមសេដ្ឋកិច្ចសំខាន់ដូចជាវិស័យទេសចរណ៍ រោងចក្រឧស្សាហកម្មសំរាប់កានាំចេញ និងវិស័យសំណង់ជាអាចបានត្រូវគេមើលឃើញថាបានទទួលរងនូវផលប៉ះពាល់ធ្ងន់ធ្ងរជាងគេ[18]។. សូមបញ្ជាក់ផងដែរថារហូតមកទល់ពេលនេះជម្ងឺកូវីត    បានបន្តមានវត្តមាននៅក្នុងប្រទេសកម្ពុជាអស់រយៈពេលជាងមួយឆ្នាំហើយ។ការអូសបន្លាយនេះវានឹងអាចធ្វើអោយមានផលប៉ះពាល់ជាអវិជ្ជមានខ្លាំងថែមទៀតមកលើសេដ្ឋកិច្ចកម្ពុជា។

នៅឆ្នាំ ២០១៩ រដ្ឋាភិបាលកម្ពុជា គ្រោងនឹងខ្ចីប្រាក់ពីដៃគូអភិវឌ្ឍន៍បរទេស ក្នុងកម្រិត ១.៤០០ លាន SDR ឬ ស្មើនឹងប្រមាណជិត ២ពាន់លានដុល្លារបន្ថែមទៀត យោងតាមសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩ ។ គិតត្រឹមខែកញ្ញា ឆ្នាំ ២០១៨ រាជរដ្ឋាភិបាលកម្ពុជា បានជំពាក់បំណុលសាធារណៈពីបរទេស មានទឹកប្រាក់សរុបប្រមាណ ៦.៨ ពាន់លានដុល្លារ រួមមាន ៤៨,៣ ភាគរយ បំណុលចិន ២៩ ភាគរយជាបំណុលទ្វេភាគីផ្សេងទៀត ៩,១ ភាគរយ ជាបំណុលចាស់ដែលកំពុងចរចាដោះស្រាយ ៥,២ ភាគរយ ជំពាក់កូរ៉េខាងត្បូង ៤,៤ភាគរយ ជំពាក់ជប៉ុន និង ៤ ភាគរយ ជាបំណុលទ្វេភាគី។[19] ទោះបីជាបំណុលសាធារណះបរទេសរបស់ប្រទេសកម្ពុជាបច្ចុប្បន្ននៅតែស្ថិតនៅក្នុងបរិបទដែលមិនទាន់មានហានិភ័យក្នុងការសងត្រឡប់វិញក៏ដោយក្តីកម្ពុជានឹងមានគំរោងបន្តបង្កើនការខ្ចីប្រាក់ពីបេទេសនេះបន្ថែមទៀត។នៅឆ្នាំ២០១៩បំណុលកម្ពុជាមានចំនួនប្រមាណជាជិត២៩%នៃGDPសរុប    ហើយចំនួននេះបានកើនឡើងដល់៣១%នោះឆ្នាំ២០២០ និងបន្តកើនឡើងជាង៣១%នៅឆ្នាំ២០២១ និងជាង៣២% នោះឆ្នាំ២០២២[20]។

## VI. គោលនយោបាយរាជរដ្ឋាភិបាលនីតិកាលទី៦៖ ការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ច

ក្នុងការអនុវត្តន៍គោលនយោបាយដើម្បីការអភិវឌ្ឍន៍ និងបម្រើប្រជាពលរដ្ឋ រាវរដ្ឋាភិបាលនីតិកាលទី៦បានគូសបញ្ជាក់នូវការធានា០៤យ៉ាង  ចំពោះរដ្ឋសភាដូចជា៖  ទី១ ការធានាការពារនូវសន្តិភាព  ស្ថិរភាព សន្តិសុខ និងសុវត្ថិភាពភូមិ/ឃុំ ការការពារឯករាជ្យអធិបតេយ្យ និងបូរណភាពទឹកដី។ ទី២ ការធានាបន្តជំរុញ

[18] Open Development Cambodia, **Socio-economic impact of COVID-19 on Cambodia, 29 September 2020, https://opendevelopmentcambodia.net/profiles/socio-economic-impact-of-covid-19-on-cambodia/**

[19] http://www.rfi.fr/km/cambodia/debt-khmer-gov-26-10-2018

[20] Statista, Cambodia: **National debt in relation to gross domestic product (GDP) from 2015 to 2025; Published by H. Plecher, Dec 1, 2020; https://www.statista.com/statistics/438792/national-debt-of-cambodia-in-relation-to-gross-domestic-product-gdp/**

អភិវឌ្ឍសេដ្ឋកិច្ច-សង្គមក្នុងគ្រប់វិស័យ ។ ទី៣ ការធានាបន្តជំរុញលើកកម្ពស់ និងកែលម្អជីវភាពរបស់ប្រជាជន។ ទី៤ ការធានានូវសុវត្ថិភាពសង្គម និងលំនឹងក្នុងការរស់នៅរបស់ប្រជាជនទាំងក្នុងពេលបច្ចុប្បន្ន ក៏ដូចជាទៅអនាគត។

អ្វីដែលគួរឲ្យកត់សម្គាល់ នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ រដ្ឋាភិបាលបានសន្យាការអនុវត្តគោលនយោបាយទាំងនោះ ដោយមិនបានកំណត់សូចនាករច្បាស់លាស់នេះទេ ពោលគឺរដ្ឋាភិបាលបានសន្យាដោយសរសេរថា «បន្តអនុវត្ត......» «ពង្រឹង......» «យកចិត្តទុកដាក់លើ.......» ជាដើម។

ចំណែកនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៩-២០២៣) រដ្ឋាភិបាល បានសសេរអំពីសូចនាករនៃការអនុវត្តគោលនយោបាយ និងការងារអាទិភាពមួយចំនួនផងដែរ ប៉ុន្តែសូចនាករទាំងនោះមិនទាន់មានភាពជាក់លាក់នៅឡើយ ដោយមិនមានគោលដៅ ពេលវេលា ឬមានចំនួនកំណត់ច្បាស់លាស់ ឬប្រៀបធៀបទៅនឹងអត្រាណាមួយច្បាស់លាស់នោះទេ។

អ្នកតាមដាន និងវិភាគបញ្ហាសង្គម[21]បានលើកឡើងថា ភាពមិនច្បាស់លាស់នៃការកំណត់សូចនាករគោលនយោបាយ ឬដំណើរនៃរាជរដ្ឋាភិបាល បានកើតចេញពីវិបត្តិនយោបាយបន្ទាប់ពីការរំលាយគណបក្សឆាំងនៅកម្ពុជាសង្គ្រោះជាតិ និងការចាប់ខ្លួនប្រធានគណបក្សនេះ ដែលធ្វើឲ្យមានការរិះគន់ពីអន្តរជាតិ។ ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចដែលកើតចេញពីសេចក្តីសម្រេចចិត្តរបស់សហភាពអឺរ៉ុប គឺជាកត្តាចម្បងមួយ ដែលដាក់ដែនកំណត់ដល់ឆន្ទៈមោះមុតរបស់រាជរដ្ឋាភិបាលក្នុងការតាក់តែងគោលនយោបាយដែលមានសូចនាការច្បាស់លាស់។ ស្របពេលជាមួយគ្នានេះដែរ ការអនុវត្តមួយជំហានម្តងៗ ដែលត្រូវបានគេហៅថា «ជំហានគីង្គក់» ត្រូវបានរាជរដ្ឋាភិបាលបន្តប្រើប្រាស់ជារបៀបដើម្បីការអភិវឌ្ឍក្នុងអំឡុងពេលមិនជាក់លាក់នេះ។ ដូចនេះ ការប្រើប្រាស់ «បន្តពង្រីក និងពង្រឹងបន្ថែម» និង « បន្តលើកស្ទួយ» នៅក្នុងការតាក់តែងគោលនយោបាយរបស់ខ្លួនត្រូវបានប្រើប្រាស់ ដើម្បីបញ្ជាក់បង្ហាញអំពីការលទ្ធផលនៃអនុវត្ត/បំពេញរបស់រដ្ឋាភិបាល ដែលមិនអាចបានកំណត់បានប្រកបដោយប្រសិទ្ធភាព។

ជាការសង្កេតឃើញជាទូទៅ វាហាក់ដូចជាមានការប្រែប្រួលតិចតួចណាស់បេប្រៀបធៀបទៅនឹងរបាយការណ៍ដែលបានរកឃើញកាលពីលើកមុន។ ពាក្យអរគុណសន្តិភាពបានត្រូវរាជរដ្ឋាភិបាលលើកយកមកធ្វើជាពាក្យស្លោកនយោបាយពេញនិយម សំរាប់បិទនៅតាមគ្រឹះស្ថានរដ្ឋ និងក្រុមហ៊ុន។ តែទោះបីជាយ៉ាងណាក៏ដោយពាក្យស្លោកនេះបានត្រូវគេរិះគន់ថា មិនបានឆ្លុះបញ្ចាំងដល់ទិដ្ឋភាពជាក់ស្តែងជាពិសេសក្រោយពេលដែលមានការរំលាយគណបក្សសង្គ្រោះជាតិកាលពីឆ្នាំ២០១៧កន្លងទៅ។ នៅពេលជាមួយគ្នានេះដែរទោះបីជាមិនមានអស្ថិរភាពសង្គមណាមួយកើតឡើងក្តី ការិតត្បិតសិទ្ធសេរីភាពនៃការជួបជុំនិងការតាមដានលើក្រុមមនុស្សដែលមាននិន្នាការមិនស្របជាមួយរដ្ឋាភិបាលបានត្រូវទទួលរងនូវការគំរាមតាមដាន និងបន្តទទួលរងនុវការចោទប្រកាន់ពីតុលាការផងដែរ។ បញ្ហាកម្ពុជាក្នុងភូមិសាស្ត្រនយោបាយក៏នៅតែមាន

---

[21] លោកបណ្ឌិត មាស នី អ្នកសិក្សាស្រាវជ្រាវ និងវិភាគបញ្ហាសង្គម

ជាបន្តជាពិសេសគឺការសង្ស័យទៅលើលទ្ធភាពនៃវត្តមានកងទ័ពចិននៅលើទឹកដីកម្ពុជា។[22]

ដោយឡែកវិស័យសេដ្ឋកិច្ចនៅក្នុងឆ្នាំ២០២០ក្រៅពីការបាត់បង់នូវការអនុគ្រោះពន្ធនាំចេញ២០%[23] ដែលសម្រេចដោយសហគមអឺរ៉ុប សេដ្ឋកិច្ចកម្ពុជាក៏ត្រូវបានទទួលនូវការវាយប្រហារយ៉ាងធ្ងន់ធ្ងរពីការរីករាលដាលនៃជម្ងឺកូវិត១៩ផងដែរ។ រោងចក្រជាច្រើនបានត្រូវបិទទ្វាក្រោមហេតុផលខ្វះវត្ថុធាតុដើម[24]។ តែការអះអាងនេះបានត្រូវអ្នកតាមដានរិះគន់ថាមកពីកត្តាវិបត្តិនយោបាយក្នុងស្រុកច្រើនជាង។

## VII. ការអនុវត្តគោលនយោបាយ "បង្កើនល្បឿនកែទម្រង់អភិបាលកិច្ច"៖ លទ្ធផល និងបញ្ហាប្រឈម

ការតាក់តែងគោលនយោបាយបង្កើនល្បឿនកែទម្រង់អភិបាលកិច្ច នៅក្នុងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី ៤ ដែលរួមមាន៖ ១.ការកែទម្រង់ និងការលើកកម្ពស់សមត្ថភាពស្ថាប័ន ២.ការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ ៣.ការពង្រឹងប្រសិទ្ធភាពអនុវត្តការងារ និង៤.ការពង្រឹងអភិបាលកិច្ចល្អក្នុងវិស័យឯកជន។

### ការកែទម្រង់ និងលើកកម្ពស់សមត្ថភាពស្ថាប័ន

ក្រសួង និងស្ថាប័ននានារបស់រាជរដ្ឋាភិបាល ត្រូវបានពង្រឹងទៅលើភាពជាម្ចាស់ ការទទួលខុសត្រូវ និងគណនេយ្យភាព សាមគ្គីភាព និងត្រូវបានលើកកម្ពស់នូវសមត្ថភាព និងគុណវុឌ្ឍិរបស់មន្ត្រីរាជការផងដែរ។ រាជរដ្ឋាភិបាលរៀបចំក្របខណ្ឌច្បាប់ និងលិខិតបទដ្ឋាន ហេដ្ឋារចនាសម្ព័នការងារ ក្រមខណ្ឌអភិវឌ្ឍមូលធនមនុស្ស និងបច្ចេកវិទ្យាព័ត៌មាន ដើម្បីលើកកម្ពស់ការគ្រប់គ្រងព័ត៌មាន និងទិន្នន័យមន្ត្រីរាជការសាធារណៈ។ ក្រោយការបោះឆ្នោតជាតិឆ្នាំ ២០១៨ រដ្ឋាភិបាលបន្តជំរុញកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដើម្បីផ្តល់អំណាចកាន់តែច្រើនដល់អាជ្ញាធរមូលដ្ឋាន។ ជាលទ្ធផល គិតត្រឹមខែធ្នូ ឆ្នាំ ២០១៩ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) បានប្រកាសថា រដ្ឋាភិបាល បានត្រៀមថវិកាជាង ៣,៥ ពាន់ពាន់លានរៀល (ជិត ៩០០ លានដុល្លារ) សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីអភិវឌ្ឍមូលដ្ឋានរបស់ខ្លួនសម្រាប់ឆ្នាំក្រោយ។[25]

---

[22] លោកបណ្ឌិត មាស នី អ្នកសិក្សាស្រាវជ្រាវ និងវិភាគបញ្ហាសង្គម

[23] On Aug 12, the European Union (EU) decision to partially withdraw Cambodia’s duty-free quota-free access to its market became effective.;

[24] https://khmer.voanews.com/a/thousands-of-workers-suspended-from-work-as-factories-face-closure-amid-virus-outbreak/5351623.html

25 Phnom Penh Post: Local administrations allocated $900M, By Mech Dara, date: 8th December 2019; https://www.phnompenhpost.com/national/local-administrations-allocated-900m?

សម្រាប់កងកម្លាំងប្រដាប់អាវុធ រាជរដ្ឋាភិបាលគ្រោងត្រូវបានបន្តកែទម្រង់លើចំណុចមួយចំនួនដូចជា ការដឹកនាំ និងការគ្រប់គ្រង ការអភិវឌ្ឍធនធានមនុស្ស និងបង្កើនសមត្ថភាពរួមទាំងផ្នែកបច្ចេកវិទ្យា ការលើកទឹកចិត្តដល់គ្រួសារកងទ័ពឲ្យរស់នៅតាមបណ្តោយព្រំដែនដើម្បីថែរក្សាបាននូវសន្តិភាព និងសុវត្ថិភាព ការបន្តចូលរួមសកម្មភាពរបស់អង្គការសហប្រជាជាតិ និងការចូលរួមសកម្មភាពគាំទ្រការអភិវឌ្ឍ និងអន្តរាគមន៍ក្នុងពេលមានគ្រោះធម្មជាតិ ផ្សេងៗ នៅឆ្នាំ ២០១៩ វិស័យកងកម្លាំងប្រដាប់អាវុធកម្ពុជា មានថវិកាសរុប ៦០៤ លានដុល្លារអាមេរិក។ សមយុទ្ធយោធានៃប្រតិបត្តិការសង្គ្រោះបន្ទាន់ ការកសាងសន្តិភាព និងការប្រយុទ្ធប្រឆាំងអំពើភេរវកម្ម ត្រូវបានធ្វើឡើង ដើម្បីធានាថាកងទ័ពបានត្រៀមខ្លួនដើម្បីបំពេញភារកិច្ចរបស់ពួកគេនៅពេលចាំបាច់។ សមយុទ្ធកងទ័ពទាំងនេះ ទោះយ៉ាងណាក៏ត្រូវទទួលរងការរិះគន់ពីសម្ព័ន្ធមិត្តលោកខាងលិចថា កម្ពុជាកំពុងរអិលចូលទៅជារណបរបស់ប្រទេសចិននៅក្នុងតំបន់។ ការចោទប្រកាន់នេះបានកើតឡើង បន្ទាប់ពីមានការសម្រេចចិត្តរបស់រដ្ឋាភិបាលកម្ពុជា ក្នុងការផ្អាកសមយុទ្ធយោធារួមគ្នាជាមួយសហរដ្ឋអាមេរិក និងការផ្អាកជំនួយមនុស្សធម៌ដទៃទៀត ដែលធ្វើឡើងដោយកងទ័ពសហរដ្ឋអាមេរិកនៅកម្ពុជា។ ដោយសារភាពតានតឹងនយោបាយផ្ទៃក្នុង និងការបញ្ចេញមតិរបស់រដ្ឋាភិបាលក្នុងការខិតទៅជិតប្រទេសចិនក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ប្រទេសកម្ពុជាបានស្ថិតនៅក្រោមបញ្ហាភូមិសាស្ត្រនយោបាយ។ ចិនបានកសាងកំពង់ផែសមុទ្រ និងទីតាំងចុះចតយាន្តអាកាសនៅខេត្តកោះកុង ដែលត្រូវបានអ្នកជំនាញយោធាមួយចំនួនអះអាងថា បម្រើដល់គោលបំណងយោធាចិនជាជាងសម្រាប់សកម្មភាពពាណិជ្ជកម្ម និងសកម្មភាពស៊ីវិល។[26] ការចាត់ទុកកម្ពុជាជាតំបន់ភូមិសាស្ត្រនយោបាយនេះកំពុងជំរុញប្រទេសតូចមួយនេះ ប្រឈមទៅនិងការយកប្រៀបគ្នាមិនត្រឹមតែក្រុមអ្នកនយោបាយខ្មែរដែលកំពុងមានវិវាទគ្នានៅក្នុងស្រុកតែប៉ុណ្ណោះ ប៉ុន្តែវាក៏ជាទីលាននៃការយកចិត្តទុកដាក់និងតាមដានពីប្រទេសមហាអំណាចផងដែរជាពិសេសសហរដ្ឋអាមេរិកនិងចិន។ អ្នកវិភាគព្រឹត្តិការណ៍នយោបាយទាំងនៅក្នុងស្រុកនិងនៅក្រៅស្រុកមួយចំនួនបានលើកឡើងថាស្ថានការណ៍បែបនេះអាចនឹងនាំកម្ពុជាអោយដើរចូលទៅជាន់ដានប្រវត្តិសាស្ត្រចាស់ ដែលបាននាំកម្ពុជាចូលទៅទៅក្នុងភ្នក់ភ្លើងសង្គ្រាមនៅទស្សវត្ស១៩៧០។ បច្ចុប្បន្នគេបានមើលឃើញថាដោយសារតែមូលហេតុភូមិសាស្ត្រនយោបាយនេះ វាអាចនឹងធ្វើឲ្យកម្ពុជាត្រូវខាតបង់នូវផលប្រយោជន៍សេដ្ឋកិច្ចនយោបាយអន្តរជាតិរួមទាំងប៉ះពាល់ដល់អធិប្បតេយ្យកម្ពុជាផងដែរ។[27]

រាជរដ្ឋាភិបាលបានដាក់ចេញអនុក្រឹត្យ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ ២០១៩ ស្តីពីការផ្ទេរធនធានបន្ថែមពីថវិការដ្ឋជូនរដ្ឋបាលឃុំ សង្កាត់សម្រាប់ចំណាយលើការអភិវឌ្ឍមូលដ្ឋានចាប់ពីឆ្នាំ ២០២០ តទៅ។ ក្នុងនោះរដ្ឋបាលឃុំ សង្កាត់នីមួយៗនឹងទទួលបានថវិកាសរុបជាមធ្យមចំនួនប្រមាណ ១២២.០០០ ដុល្លារអាមេរិក ដែលក្នុងនោះថវិកាផ្នែកអភិវឌ្ឍន៍មូលដ្ឋានមានចំនួនជាមធ្យមប្រមាណជាង ៧០.០០០ ដុល្លារអាមេរិកក្នុងឆ្នាំ

[26] Kyodo News: Chinese Project in Cambodia raises alarms of Military build up, August 12th 2019; https://english.kyodonews.net/news/2019/08/2a1e00ec3d97-focus-chinese-project-in-cambodia-raises-alarms-of-military-build-up.html

[27] អ្នកសិក្សាស្រាវជ្រាវការអភិវឌ្ឍន៍សង្គម បណ្ឌិត មាស នី

២០២០ (កើនឡើងទ្វេដងធៀបនឹងឆ្នាំ ២០១៩) ហើយថវិកានេះនឹងកើនឡើងជាបន្តបន្ទាប់រៀងរាល់ឆ្នាំ។ តាមការប៉ាន់ប្រមាណរហូតដល់ឆ្នាំ ២០២៣ រដ្ឋបាលឃុំ សង្កាត់នីមួយៗនឹងទទួលបានថវិកាសរុបជាមធ្យម ចំនួនប្រមាណ ១៩៣.០០០ ដុល្លារអាមេរិក ដែលក្នុងនោះថវិកាផ្នែកអភិវឌ្ឍន៍មូលដ្ឋានមានចំនួនជាមធ្យម ប្រមាណជាង ១៣២.០០០ ដុល្លារអាមេរិក។

ទោះបីយ៉ាងនេះក្តី រហូតមកដល់ដំណាក់កាលនេះ ការបែងចែកថវិកានេះនៅតែមិនទាន់ច្បាស់អំពីរបៀប ប្រើប្រាស់ថវិកាទាំងនោះនៅថ្នាក់មូលដ្ឋាន។ ទន្ទឹមនឹងនេះការបង្កើនថវិកាដល់ឃុំ/សង្កាត់ បានធ្វើឱ្យមានការព្រួយបារម្ភបន្ថែមទៀតអំពីសមត្ថភាពរបស់ឃុំ/សង្កាត់នៅមូលដ្ឋានក្នុងការគ្រប់គ្រងថវិកា ប្រកបដោយតម្លាភាពនិងមានគណនីភាពគ្រប់គ្រាន់។ គេនៅតែមានការព្រួយបារម្ភអំពីការពង្រឹងការគាំទ្រផ្នែកបច្ចេកទេស និងសមត្ថភាពដល់រដ្ឋបាលឃុំ សង្កាត់ ដើម្បីធានាឱ្យបានថា រដ្ឋបាលឃុំ សង្កាត់នីមួយៗអាចគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ថវិការបស់ខ្លួនស្របតាមគោលការណ៍ និងនីតិវិធីជាធរមានប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព ឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍ជាក់ស្តែងនៅតាមមូលដ្ឋាននីមួយៗ និងដោយមានការចូលរួមតាមដានត្រួតពិនិត្យពីប្រជាពលរដ្ឋដោយផ្ទាល់ផងដែរ។[28] អវត្តមាននៃក្រុមប្រឹក្សាឃុំសង្កាត់ពី គណបក្សប្រឆាំងដែលត្រូវបានគេរំលាយ ជាការបាត់បង់នូវយន្តការ ដ៏មានសក្តានុពលមួយ ដើម្បីធ្វើការត្រួតពិនិត្យអំពីរបៀបដែលថវិកាត្រូវបានចំណាយអោយបានត្រឹមត្រូវ។ បញ្ហានេះអាចនឹងមានកាន់តែធ្ងន់ធ្ងរទៅទៀត ដោយសារតែក្រុមប្រឹក្សាឃុំមូលដ្ឋានខ្លះបានយកតួនាទីខ្លួនទៅបំរើសកម្មភាព និងផលប្រយោជន៍គណបក្សជាជាងផលប្រយោជន៍ជាតិ។

ការអភិវឌ្ឍន៏នៅមូលដ្ឋាននេះ ក៏ត្រូវបានទទួលរងនូវផលប៉ះពាល់ខ្លាំងផងដែរដោយសារតែការដកនូវជំនួយបរទេសជាពិសេសប្រទេសស៊ុយអែត ដែលបានផ្តោតទៅលើការកសាងប្រជាធិបតេយ្យមូលដ្ឋាន និងសិទ្ធិមនុស្ស[29]។ កាលពីចុងឆ្នាំ២០២០កន្លងទៅប្រទេសនេះ បានសម្រេចដកចេញនូវជំនួយថវិកាប្រមាណជា២៣លានដុល្លា ដែលថវិការភាគច្រើនផ្តល់ទៅអោយក្រសួងមហាផ្ទៃក្នុងកិច្ចការខំប្រឹងប្រែងដើម្បីធ្វើការកំណែរទម្រង់អភិបាលកិច្ចល្អ និងធ្វើអោយបានប្រសើរឡើងដល់ការអនុវត្តន៏ដំណើរការប្រជាធិបតេយ្យនៅថ្នាក់ឃុំសង្កាត់។

ផ្នែកមួយនៃការកសាងសមត្ថភាពនៃការគ្រប់គ្រងថ្នាក់ក្រោមជាតិ គឺបង្កើតឲ្យមានការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងបានធ្វើប្រតិភូកម្មមុខងារផ្តល់សេវារដ្ឋបាលចំនួន ២១១ ប្រភេទ សេវាលើវិស័យជំនាញចំនួន ១០ គិតមកដល់បំណាច់ឆ្នាំ ២០១៩ នេះ។ មកដល់ពេលបច្ចុប្បន្ន ការិយាល័យច្រកចេញចូលតែមួយ ថ្នាក់រដ្ឋបាលក្រុង ស្រុក ខណ្ឌមានចំនួន១១៥ ក្នុងចំណោមក្រុង ស្រុក ខណ្ឌ ចំនួន ២០៣ នៃរាជធានី ខេត្តទាំង ២៥ ដែលក្នុងនោះរួមមានរដ្ឋបាលក្រុង ចំនួន

---

[28] គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) បើកកិច្ចប្រជុំលើកទី១៧, ដោយ៖ នាយកដ្ឋានព័ត៌មានវិទ្យា, November 20, 2019, https://www.interior.gov.kh/news/detail/1262

[29] Voice of Democracy (VOD): **Sweden to Refocus Cambodia Aid Due to Rights Concerns, Friday June 12, 2020;** https://vodenglish.news/sweden-to-refocus-cambodia-aid-due-to-rights-concerns/

២៧ រដ្ឋបាលស្រុកចំនួន ៧៤ និងរដ្ឋបាលខណ្ឌ ចំនួន ១៤ ស្មើនឹង ៥៧% នៃចំនួនរដ្ឋបាលក្រុង ស្រុក ខណ្ឌ ទូទាំងប្រទេស[30]។

នៅចុងឆ្នាំ២០២០កន្លងទៅ ក្រសួងមហាផ្ទៃបានដាក់ចេញនូវវិធានការថ្មីមួយដើម្បីលើកកម្ពស់ការអនុវត្តន៍ដំណើរការច្រកចេញចូលតែមួយតាមរយៈការប្រើប្រាស់នូវប្រព័ន្ធឌីជីថលសំរាប់អោយអ្នកប្រើប្រាស់អាចធ្វើការតាមដាននូវការវិត្តន៏នៃសំណើរសុំរបស់ខ្លួនតាមរយៈប្រព័ន្ធអ៊ីនធឺណែត។ នេះជាលើកដំបូងហើយដែល ក្រសួងបានដាក់ចេញនូវប្រព័ន្ធបច្ចេកវិទ្យាសំរាប់សម្រួលដល់ការអនុវត្តន៍ប្រើប្រាស់ដំណើរការច្រកចេញចូលតែមួយនេះ[31]។ ការផ្តល់ការហ្វឹកហ្វឺនជាច្រើនបានត្រូវគេធ្វើឡើងដល់មន្ត្រីពាក់ព័ន្ធលើរបៀបនៃការការប្រើប្រាសើបញព័ន្ធថ្មីនេះ។

## ការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ

ក្នុងនីតិកាលទី៦នៃរដ្ឋសភា រាជរដ្ឋាភិបាលបន្តអនុវត្តផែនការយុទ្ធសាស្ត្រជាតិ «មិនហ៊ាន មិនអាច និងមិនចង់» ប្រព្រឹត្តអំពើពុករលួយ តាមរយៈសកម្មភាពអប់រំ បង្ការ ទប់ស្កាត់ និងបង្ក្រាប។ រាជរដ្ឋាភិបាលបន្តពង្រឹង និងពង្រីកការផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានអំពីសេវាសាធារណៈ លិខិតបទដ្ឋានគតិយុត្តិ និងឯកសារគោលនយោបាយជាតិ និងយន្តការអធិការកិច្ច និងសវនកម្ម និងជំរុញការអនុវត្តយន្តការទទួលព័ត៌មានត្រលប់នៃការផ្តក់សេវាក្នុងវិស័យសាធារណៈ។ បន្ថែមលើសពីនេះទៀត រាជរដ្ឋាភិបាល នឹងជំរុញឲ្យមានការចូលរួមពីប្រជាជនក្នុងដំណើរការនៃការអភិវឌ្ឍនានា និងការអនុវត្តក្រមសីលធម៌ការងារ និងគោលការណ៍វិសមិតភាពមុខងារ និងទំនាស់ផលប្រយោជន៍ក្នុងមុខងារសាធារណៈ។

ក្នុងគោលបំណងបង្ហាញពីកិច្ចខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការប្រឆាំងអំពើពុករលួយ នៅដើមឆ្នាំ ២០១៩ មេបញ្ជាការកងរាជអាវុធហត្ថខេត្ត រតនគិរី និងស្នងការរងខេត្ត កណ្តាល ត្រូវបានសាធារណជនដាក់ការសង្ស័យ ថាអាចជាប់ពាក់ព័ន្ធនឹងអំពើពុករលួយ ក្រោយពេលបង្ហោះវីដេអូលើបណ្តាញសង្គម បង្ហាញអំពីប្រើប្រាស់ទ្រព្យសម្បត្តិដ៏ច្រើនសន្ធឹកសន្ធាប់របស់ខ្លួន។ អង្គភាពប្រឆាំងអំពើពុករលួយ (ACU) បានបើកការស៊ើបអង្កេតលើករណីទាំងពីរខាងលើ។ លទ្ធផលនៃការស៊ើបអង្កេតរបស់អង្គភាពប្រឆាំងអំពើពុករលួយ បានឲ្យដឹងថា ករណីខាងលើមិនមែនជាករណីបទល្មើសពុករលួយទេ គឺការសំញ៉ែងទ្រព្យសម្បត្តិរបស់ខ្លួន ប៉ុន្តែមេ

[30] រដ្ឋបាលខេត្តកំពត រៀបចំសិក្ខាសាលាបូកសរុបលទ្ធផលការងារឆ្នាំ ២០១៩ និងលើកទិសដៅការងារឆ្នាំ ២០២០ នៃការអនុវត្តការងារច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ រដ្ឋបាលខេត្តកំពត https://www.interior.gov.kh/report/detail/4379 , February 24, 2020

[31] The Phnom Penh Post: New programme set to track, manage One Window service, 02 September 2020, by Long Kimmarita; https://www.phnompenhpost.com/national/new-programme-set-track-manage-one-window-service

បញ្ជាការកងរាជអាវុធហត្ថខេត្ត រតនគិរី ត្រូវបានព្រះមហាក្សត្រ ចេញព្រះរាជក្រឹត្យលុបឈ្មោះចេញពីក្របខណ្ឌកងយោធពលខេមរភូមិន្ទផងដែរ។[32]

សន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយរបស់អង្គការតម្លាភាពអន្តរជាតិ គឺជាសូចនាករកម្រិតសកលឈានមុខ ទាក់ទងនឹងអំពើពុករលួយនៅក្នុងវិស័យសាធារណៈ ដោយបង្ហាញពីកម្រិតនៃអំពើពុករលួយប្រចាំឆ្នាំរបស់ប្រទេសជាច្រើនជុំវិញពិភពលោក។ យោងតាមលទ្ធផលសន្ទស្សន៍ក្នុងឆ្នាំ ២០១៩ បានបង្ហាញថា ប្រទេសកម្ពុជាទទួលបាន ២០ពិន្ទុ លើពិន្ទុអតិបរមា ១០០ គឺជាពិន្ទុដដែលធៀបនឹងឆ្នាំ ២០១៨ ។ កម្ពុជាឈរនៅចំណាត់ថ្នាក់ទី ១៦២ ក្នុងចំណោមប្រទេស និងដែនដីសរុបចំនួន ១៨០ ដែលត្រូវបានដាក់បញ្ចូលក្នុងការវាយតម្លៃ។ នៅកម្រិតតំបន់ ប្រទេសកម្ពុជាបន្តស្ថិតក្នុងចំណោមប្រទេសមានពិន្ទុទាបជាងគេទី ៣ នៅតំបន់អាស៊ីប៉ាស៊ីហ្វិច នៅលើតែប្រទេសអាហ្វហ្គានីស្ថាន និងកូរ៉េខាងជើងតែប៉ុណ្ណោះ ហើយក៏ជាប្រទេសមានពិន្ទុទាបជាងគេបំផុតក្នុងតំបន់អាស៊ានផងដែរ33។

សម្រាប់ឆ្នាំ២០២០ លទ្ធផលនៃសន្ទស្សន៍បង្ហាញថា ប្រទេសកម្ពុជាទទួលបាន ២១ពិន្ទុ លើពិន្ទុអតិបរមា ១០០ ដែលជាការកើន១ពិន្ទុ ចាប់តាំងពីឆ្នាំ២០១៨។ កម្ពុជាឈរនៅចំណាត់ថ្នាក់ទី១៦០ ក្នុងចំណោមប្រទេស និងដែនដីសរុបចំនួន ១៨០ ដែលត្រូវបានដាក់បញ្ចូលក្នុងការវាយតម្លៃ។ ដូចគ្នានឹងឆ្នាំមុនដែរ នៅកម្រិតតំបន់ ប្រទេសកម្ពុជាបន្តស្ថិតក្នុងចំណោមប្រទេសមានពិន្ទុទាបជាងគេទី៣ នៅតំបន់អាស៊ីប៉ាស៊ីហ្វិច នៅលើតែប្រទេសអាហ្វហ្គានីស្ថាន និងកូរ៉េខាងជើងតែប៉ុណ្ណោះ ហើយក៏ជាប្រទេសមានពិន្ទុទាបជាងគេបំផុតក្នុងតំបន់អាស៊ានផងដែរ។

លទ្ធផលរបស់ប្រទេសកម្ពុជាបានឆ្លុះបញ្ចាំងពីភាពប្រសើរឡើងមួយចំនួន រួមមានកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយអំពើពុករលួយក្នុងវិស័យឯកជន កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមរយៈការពង្រឹងការកៀរគរធនធាន ការជំរុញឱ្យមានរដ្ឋាភិបាលតាមប្រព័ន្ធអេឡិចត្រូនិក និងលើកកម្ពស់សេវាសាធារណៈ ជាពិសេសការឆ្លើយតបទៅនឹងវិបត្តិជំងឺកូវីដ-១៩។ ប៉ុន្តែ ការប្រសើរឡើងនេះមិនទាន់បានផ្លាស់ប្តូរទស្សនៈយល់ឃើញជារួមរបស់អ្នកជំនាញ និងធុរជននោះទេ ជាពិសេសទៅលើកំណែទម្រង់រចនាសម្ព័ន្ធ និងជាប្រព័ន្ធជុំវិញបញ្ហាអំពើពុករលួយទ្រង់ទ្រាយធំ និងអំពើពុករលួយផ្នែកនយោបាយ និងការពង្រឹងនីតិរដ្ឋ ត្រូវបានចាត់ទុកថានៅមិនទាន់មានភាពប្រសើរឡើងនៅឡើយ។ ជាក់ស្តែង ប្រទេសកម្ពុជានៅតែទទួលបានពិន្ទុទាបខ្លាំង ក្នុងសន្ទស្សន៍ស្តីពីនីតិរដ្ឋរបស់គម្រោងយុត្តិធម៌ពិភពលោក (WJP) ឆ្នាំ២០២០ និងគម្រោងនៃភាព

---

[32] មេPMខេត្តរតនៈគិរីត្រូវបានព្រះមហាក្សត្រចេញព្រះរាជក្រឹត្យលុបឈ្មោះចេញពីក្របខណ្ឌកងខេមរភូមិន្ទថ្ងៃសៅរ៍ ទី9 ខែកុម្ភៈ ឆ្នាំ 2019 https://postnews.com.kh/local/412593

[33] សន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយ២០១៩, 23 JAN 2020 https://www.ticambodia.org/cpi2019/

ផ្សេងគ្នានៃប្រជាធិបតេយ្យ (VDEM) ឆ្នាំ២០២០ ដែលវាស់វែងពីកិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសនីមួយៗ ក្នុងការកែលម្អនីតិរដ្ឋ និងការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យ។[34]

ចំណែកឯអ្នកឃ្លាំមើល និងតាមដានបញ្ហាសង្គមបានលើកឡើងថា បញ្ហាប្រយុទ្ធប្រឆាំងអំពើពុករលួយនៅកម្ពុជា គឺបានអនុវត្តមិនបានទូលំទូលាយ និងពេញលេញនៅឡើយ ពោលពឹងផ្អែកលើពាក្យបណ្តឹង និងអនុវត្តបានតែលើមន្ត្រីថ្នាក់ក្រោមស្របពេល ដែលទំហំទ្រព្យសម្បត្តិរបស់មន្ត្រីនយោបាយធំៗតែងតែត្រូវបានទទួលរងការរិះគន់ពីសាធារណជនមិនត្រូវបានគេយកមកធ្វើការស៊ើបអង្កេត។ បើទោះបីជាមានសកម្មភាពប្រឆាំង និងបង្ក្រាបបទល្មើសពុករលួយរបស់អង្គភាពប្រឆាំងអំពើពុករលួយ(ACU) នាពេលកន្លងមកនេះ សកម្មភាពទាំងនោះនៅមិនទាន់ឆ្លើយតបទៅនឹងទំហំនៃអំពើពុករលួយ ដែលប្រព្រឹត្តឡើងដោយមន្ត្រីរាជការទាំងស៊ីវិល និងយោធានៅឡើយទេ[35]។

លើសពីនេះទៀតអំពើរពុករលួយជាប្រព័ន្ធបានតើត្រូវគេលើកឡើងយកមកអធិប្បាយស្តីអំពី ស្ថានភាពពុករលួយនៅកម្ពុជាដោយក្នុងនោះមានមន្ត្រីជាន់ខ្ពស់រាជរដ្ឋាភិបាលសំខាន់ៗមួយចំនួន បានត្រូវគេតាមដានរកឃើញថាបាននាំចេញនូវទឹកប្រាក់រាប់សិបលានដុល្លា ពីប្រទេសកម្ពុជាទៅសាងសង់ក្រុមហុនជំនួញធំៗនៅបរទេស។ ទោះបីជាការរកឃើញនេះបានផ្តល់នូវភស្តុតាងច្បាស់លាស់យ៉ាងណាហើយក្តីក៏គេមិនឃើញមានចំណាត់ការណាមួយដែលរដ្ឋភិបាលបានធ្វើឡើងដើម្បីស៊ើបអង្កេតលើករណីយដែលបានរ ឃើញទាំងនេះនៅឡើយទេ។[36]

ទោះបីជាយ៉ាងណាក៏ដោយ ផ្ទុយពីការលើកឡើងខាងលើ អ្នកនាំពាក្យរាជរដ្ឋាភិបាលយល់ថា ស្ថានភាពនៃការប្រយុទ្ធប្រឆាំងអំពើពុករលួយនៅកម្ពុជាកាន់តែមានភាពល្អប្រសើរឡើង ប៉ុន្តែលោកក៏ទទួលស្គាល់ផងដែរថា វាមិនទាន់អស់នៅឡើយទេ។ រដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តក្នុងការបោសសម្អាតអំពើពុករលួយនេះដោយមានទាំងការបង្ក្រាប និងការបណ្តុះនូវវប្បធម៌សុចរិត និងតម្លាភាព[37]។ ការខ្វះខាតនៃការពង្រឹងអនុវត្តច្បាប់ និងភាពទន់ខ្សោយនៅក្នុងប្រព័ន្ធយុត្តិធម៌ បក្សពួកនិយម ក៏ដូចជាកង្វះខាតនៃគណនេយ្យភាពនៅក្នុងប្រព័ន្ធនយោបាយ គឺជាបញ្ហាសំខាន់ ដែលរួមចំណែកដល់ការអសមត្ថភាពរបស់រដ្ឋាភិបាលក្នុងការលុបបំបាត់អំពើពុករលួយនេះ។

---

[34] https://www.ticambodia.org/kh/cpi2020/

[35] Also see in: The Diplomat: The Truth About Cambodia's So-Called Corruption Crackdown, by David Hutt, August 28th 2019; https://thediplomat.com/2019/08/the-truth-about-cambodias-so-called-corruption-crackdown/

[36] អ្នកសិក្សាស្រាវជ្រាវការអភិវឌ្ឍន៍សង្គម បណ្ឌិត មាស នី

[37] Khmer Time: **Rising corruption in Cambodia: Who, What, Why and How?, by Taing Rinith, January 30, 2020; https://www.khmertimeskh.com/685222/rising-corruption-in-cambodia-who-what-why-and-how/**

## ការពង្រឹងប្រសិទ្ធភាពអនុវត្តការងារ

ការបន្តដំឡើងបៀវត្ស និងប្រាក់សោធនិវត្ត ជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធត្រូវបានរាជរដ្ឋាភិបាលចាត់ទុកថាជាផ្នែកមួយនៃគោលនយោបាយពង្រឹងប្រសិទ្ធភាពអនុវត្តការងារផងដែរ។ ហើយការធ្វើប្រតិភូកម្មតាមរយៈយន្តការវិមជ្ឈការ និងសហវិជ្ឈការចំពោះស្ថាប័នរបស់ជាតិគ្រប់កម្រិតទៅលើអំណាចមុខងារ ធនធាន ដើម្បីទទួលបានស្វ័យភាពសមស្របក៏ត្រូវបានគេធ្វើឡើងដែរ។ រដ្ឋាភិបាលនឹងដាក់អនុវត្តនូវប្រព័ន្ធតាមដាន និងវាយតម្លៃដែលមានសូចនាករច្បាស់លាស់ក្នុងការងារគ្រប់គ្រងស្ថាប័នសាធារណៈ។ ទោះយ៉ាងណា ការប៉ុនប៉ងខាងលើត្រូវបានគេអះអាងថា មានចំណុចខ្សោយច្រើននៅឡើយ ហើយមិនទាន់មានប្រសិទ្ធភាពគ្រប់គ្រាន់នៅឡើយទេ។ ពោលគឺត្រូវគេសង្កេតឃើញថាប្រព័ន្ធរដ្ឋាភិបាលបច្ចុប្បន្ននៅតែត្រូវបានបន្តត្រួតត្រាដោយអ្នកនយោបាយ ហើយប្រព័ន្ធរបស់រដ្ឋក៏ត្រូវបានគេប្រើធ្វើជាឧបករណ៍នយោបាយយ៉ាងខ្លាំងក្លាផងដែរ។ ការអនុវត្តន៍បែបនេះហាក់ដូចជាកំពុងបានកើនឡើងក្នុងខណៈដែលមានការបញ្ចូល អ្នកនយោបាយវ័យក្មេងថ្មីៗថែមទៀតចូលទៅក្នុងប្រព័ន្ធនយោបាយ ហើយកត្តានេះវាបានបណ្តាលអោយមានភាពអសកម្មខ្លះៗទៅលើដំណើរការជាប្រក្រតីរបស់ប្រព័ន្ធគ្រប់គ្រងផ្នែកបច្ចេកទេសរបស់រដ្ឋ នៅពេលដែលអ្នកនយោបាយព្យាយាមប្រើតួនាទីរបស់ខ្លួនហួសដែនសមត្ថកិច្ចនៅក្នុងពេលខ្លះ[38]។ នៅក្នុងករណីយខ្លះ ការធ្វើប្រតិភូកម្មដោយខ្វះកាតត្រួតពិនិត្យតឹងរឹង និងកែតំរូវអោយទាន់ពេលវេលាវាក៏បានបណ្តាលអោយកើតមានអំពើជិះជាន់ផ្សេងៗកើតមានដល់ប្រជាពលរដ្ឋស៊ីវិលផងដែរ។ សូមបញ្ជាក់ផងដែរថានៅក្នុងឆ្នាំ២០២០ នេះអង្គការ Freedom House, បានដាក់ពិន្ទុអោយកម្ពុជានៅចំណាត់ថ្នាក់២៥លើ១០០ថាជាប្រទេសដែលមានការរិតត្បិតខ្លាំងទៅលើសិទ្ធសេរីភាពជាមូលដ្ឋានរបស់ពលរដ្ឋ[39]។

រាជរដ្ឋាភិបាលលើកកម្ពស់សេវាយុត្តិធម៌ ដោយបង្កើនប្រសិទ្ធិភាពការងាររបស់មន្ត្រីអនុវត្តច្បាប់ ពង្រឹងជំនឿទុកចិត្តពីសាធារណជន និងប្រយុទ្ធប្រឆាំងនិងអំពើអយុត្តិធម៌នៅក្នុងសង្គម តាមរយៈការពង្រឹងការអនុវត្តច្បាប់ឲ្យបានត្រឹមត្រូវ ការពង្រឹងនូវភាពស្អាតស្អំ និងក្រមសីលធម៌វិជ្ជាជីវៈរបស់មន្ត្រីក្នុងការអនុវត្តច្បាប់ ការពង្រឹងយន្តការវិន័យការងារ ការធ្វើទំនើបកម្មរដ្ឋបាលយុត្តិធម៌ ការលើកកម្ពស់ការផ្តល់សេវាច្បាប់ និងការពង្រឹង និងកែលម្អយន្តការដោះស្រាយវិវាទជាដើម។

ដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធយុត្តិធម៌នៅក្នុងប្រទេស ក្រុមមេធាវីរបស់រដ្ឋាភិបាលត្រូវបានបង្កើតឡើង និងស្ថិតនៅក្រោមការណែនាំផ្ទាល់របស់នាយករដ្ឋមន្ត្រីដើម្បីផ្តល់ការគាំទ្រផ្នែកច្បាប់ដល់ជនក្រីក្រ។ កិច្ចខិតខំប្រឹងប្រែងនេះត្រូវបានគេរិះគន់ ថាជាការជ្រៀតជ្រែកចូលរបស់អ្នកនយោបាយទៅក្នុងប្រព័ន្ធយុត្តិធម៌បច្ចុប្បន្នពីព្រោះមេធាវីទាំងនេះអាចប្រើប្រាស់ទំនាក់ទំនងរបស់ពួកគេជាមួយនាយករដ្ឋមន្ត្រីដើម្បីអោយមានអំណាចនិងឥទ្ធិពលលើសេចក្តីសម្រេចរបស់តុលាការ។

---

[38] Also see: https://freedomhouse.org/country/cambodia/freedom-world/2020

[39]https://freedomhouse.org/country/cambodia/freedom-world/2020

លើសពីនេះទៀត ដំណើរការនៃប្រព័ន្ធយុត្តិធម៌កម្ពុជានាពេលបច្ចុប្បន្ន នៅតែបង្កក្ដីកង្វល់ដ៏ធំធេងនៅឡើយ។ កង្វះឯករាជ្យភាពរបស់តុលាការដោយសារតែឥទ្ធិពល នៃប្រព័ន្ធនយោបាយ ត្រូវបានគេអះអាងថាជាបញ្ហាគន្លឹះដែលធ្វើឱ្យអន្តរាយដល់ប្រព័ន្ធយុត្តិធម៌នៅកម្ពុជា។ អំពើពុករលួយ និងកង្វះការទុកចិត្តពីប្រជាជនក៏ត្រូវចាក់ឫសក្នុងប្រព័ន្ធយុត្តិធម៌នៅកម្ពុជាផងដែរ។ លោក ណាន់ សេរីវ័ន្ត អ្នកសរសេរប្លុកនយោបាយ និងអ្នកសកម្មក្នុងការជជែកបញ្ហានយោបាយបានលើកឡើងថា «ប្រជាពលរដ្ឋមិនជឿជាក់លើការអនុវត្តច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅកម្ពុជាទេ»។[40] ជាការបូកសរុបក្នុងរបាយការណ៍លើកនេះទោះបីជាមានការការខំប្រឹងប្រែងដើម្បីធ្វើការកំណែរទម្រង់ដល់ប្រព័ន្ធច្បាប់និងប្រព័ន្ធយុត្តិធម៌ហើយក្តី[41] ក៏យើងនៅតែអាចសន្និដ្ឋានបានថារាជរដ្ឋាភិបាលហាក់ដូចជាមិនបានបង្ហាញអោយឃើញនូវលទ្ធផលកែប្រែណាមួយជាដុំកំភួន ដើម្បីធ្វើអោយបានប្រសើរឡើងនូវដល់ការងាររបស់ប្រព័ន្ធយុត្តិធម៌កម្ពុជាក្នុងការជៀសចេញពីការជ្រៀតជ្រែករបស់អ្នកនយោបាយនៅឡើយទេ[42]។

## ការពង្រឹងអភិបាលកិច្ចល្អវិស័យឯកជន

ទាក់ទងនិងវិស័យឯកជន រាជរដ្ឋាភិបាលនឹងសិក្សា និងរៀបចំក្របខណ្ឌគោលនយោបាយលើកកម្ពស់អភិបាល និងការទទួលខុសត្រូវផ្នែកសង្គម និងបរិស្ថាន(Corporate's social and environmental responsibility) ដើម្បីចូលរួមដោះស្រាយបញ្ហាសង្គម បរិស្ថាន និងតម្លៃវប្បធម៌។ ដើម្បីការពារសិទ្ធិ និងសុវត្ថិភាពអតិថិជន រាជរដ្ឋាភិបាលនឹងជំរុញរៀបចំ និងអនុម័តច្បាប់ស្តីពីការការពារអតិថិជន (Consumer Protection Law)។ នៅក្នុងវិស័យឯកជនក្នុងប្រព័ន្ធជាផ្លូវការ ដូចជានៅក្នុងរោងចក្រកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង ការខិតខំប្រឹងប្រែងក្នុងការកែលម្អមួយចំនួនត្រូវបានបង្កើតឡើង ហើយចំណុចកែលម្អមួយចំនួនត្រូវបានដាក់ចូលនៅក្នុងច្បាប់ស្តីពីការងារ ដើម្បីធានាថាសិទ្ធិការងារត្រូវបានគោរព និងកម្មករមានសិទ្ធិចូលរួមវិភាគទានក្នុងមូលនិធិសន្តិសុខសង្គម ដែលពួកគេអ្នកទទួលបានត្រលប់មកវិញ នូវការធានារ៉ាប់រងផ្នែកសុខភាពរបស់ពួកគេ។

ទោះយ៉ាងណា សិទ្ធិកម្មករនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងបានប្រឈមនឹងបញ្ហាសំខាន់ៗមួយចំនួនដូចជា៖ ប្រាក់ខែកម្ម ករនៅតែទាប ការធ្វើការលើសម៉ោងដោយគ្មានប្រាក់ឈ្នួល ដែលត្រូវបានគេសង្កេតឃើញកើតមានឡើងបន្ទាប់ពីការបោះឆ្នោតឆ្នាំ ២០១៨ ។ បញ្ហានេះបន្តកើតឡើងកាន់តែធ្ងន់ធ្ងរថែមទៀត ដោយសាររដ្ឋាភិបាលប៉ុនប៉ងធ្វើឱ្យតួនាទីរបស់សហជីពចុះខ្សោយតាមរយៈការបែងចែក

[40] Quoted by Asia Times: The injustice of Cambodian justice, by David Hutt, May 17th , 2019; https://asiatimes.com/2019/05/the-injustice-of-cambodian-justice/

[41] KONG Phallack; OVERVIEW OF THE CAMBODIAN LEGAL AND JUDICIAL SYSTEM and Recent Efforts at Legal and Judicial Reform, http://www.khmerlex.com/Site/images/library_file/10-Overview%20of%20the%20Cambodian%20Legal%20and%20Judicial.pdf

[42] Also see: https://www.licadho-cambodia.org/topic/rule_of_law

និងគ្រប់គ្រងរវាងសហជីពកម្មករឯករាជ្យ និងសហជីពដែលគាំទ្រដោយរដ្ឋាភិបាល។[43] បណ្ដឹងនៅតុលាការដែលចោទប្រកាន់មេដឹកនាំសហជីពនៅតែបន្តកើតមាន ជាពិសេសបណ្ដឹងប្រឆាំងមេដឹកនាំសហជីពឯករាជ្យសំខាន់ៗមួយចំនួន។

សម្រាប់ប្រាក់ឈ្នួលអប្បបរមាឲ្យកម្មករ ឆ្នាំ ២០១៩ ក្រសួងការងារកំណត់ ១៨២ ដុល្លារ និងត្រូវបើកជា ពីរដងក្នុងមួយខែ ដែលកើនឡើងចំនួន ១២ ដុល្លារ បើប្រៀបធៀបនឹងឆ្នាំ ២០១៨ ដែលមានត្រឹមតែ ១៧០ ដុល្លារក្នុងមួយខែ។ ទោះមានការកើនឡើងជាងឆ្នាំ ២០១៨ ក្ដី ចំនួនប្រាក់ឈ្នួលអប្បបរមានេះមិនត្រូវបានទទួលការសាទរពីគ្រប់សហជីព និងសង្គមស៊ីវិលឃ្លាំមើលសិទ្ធិការងារនៅកម្ពុជានោះនៅឡើយទេ ដោយសារពួកគេបានវាយតម្លៃថាប្រាក់ឈ្នួល ១៨២ ដុល្លារអាមេរិក ក្នុងមួយខែ មិនទាន់ឆ្លើយតបនឹងតម្រូវការជីវភាពរស់នៅពិតប្រាកដរបស់កម្មករទេ។[44] មាត្រា១០៤ នៃច្បាប់ស្ដីពីការងារចែងថា ប្រាក់ឈ្នួលកម្មករយ៉ាងហោចណាស់ ត្រូវរ៉ាប់រងកម្មករនិយោជិក គ្រប់រូបឲ្យមានកម្ពស់ជីវភាពសមរម្យទៅតាមសេចក្ដីថ្លៃថ្នូររបស់មនុស្ស។

ក្នុងឆ្នាំ២០២០ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ប្រកាសថាប្រាក់ឈ្នួលអប្បបរមារបស់កម្មករនិយោជិតផ្នែកវាយនភណ្ឌកាត់ដេរនិងផលិតស្បែកជើង គឺ១៩០ដុល្លាក្នុងមួយខែ ដែលត្រូវអនុវត្តន៍ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០តទៅ ស្របពេលដែលកម្ពុជា និងពិភពលោកកំពុងប្រឈមមុខនឹងបញ្ហាកូវិដ ១៩។ ការតំឡើងប្រាក់ឈ្នួលនោះបានធ្វើឲ្យតំណាងសមាគមរោងចក្រ ក៏ស្នើទៅរដ្ឋាភិបាលបញ្ចុះតម្លៃពន្ធលើប្រាក់ចំណេញ បញ្ចុះតម្លៃអគ្គិសនី និងស្នើឲ្យកម្មករបង្កើនផលិតភាពតាមរយៈកាត់បន្ថយថ្ងៃឈប់សម្រាកជាដើម។ ចំណែកប្រធានសហភាពការងារកម្ពុជាលោក អាត់ ធន់ មិនពេញចិត្តនឹងការដំឡើងប្រាក់ឈ្នួលអប្បបរមាជូនកម្មករនៅឆ្នាំនេះទេ ដោយថា អតិផរណាកើនឡើង ការរស់នៅរបស់កម្មករជួបភាពលំបាក និងមានបញ្ហាផ្សេងៗទៀត ។[45]

នៅក្នុងឆ្នាំ ២០១៩ ច្បាប់ស្ដីពីរបបសន្តិសុខសង្គមថ្មីត្រូវបានប្រកាសឱ្យប្រើប្រាស់ ដែលគ្របដណ្ដប់ទៅលើការគាំពារចំនួន ៤ផ្នែក រួមមាន (១)ផ្នែកប្រាក់សោធន (២)ផ្នែកថែទាំសុខភាព (៣)ផ្នែកហានិភ័យការងារ និង (៤)ផ្នែកនិកម្មភាពការងារ សម្រាប់បុគ្គលដែលស្ថិតក្នុងវិស័យសាធារណៈ បុគ្គលដែលស្ថិតក្រោមច្បាប់ស្ដីពីការងារ រួមទាំងបុគ្គលិកផ្លូវអាកាស នាវាសមុទ្រ និងអ្នកបម្រើតាមផ្ទះ ព្រមទាំងបុគ្គលស្វ័យនិយោជ

[43] Some Independent worker unions are placed in the government back list, as part of the Color revolution, to over thrown the government.

[44] ប្រាក់ឈ្នួលអប្បបរមាក្នុងឧស្សាហកម្មកាត់ដេរនឹងត្រូវបានដំឡើងដល់១៨២ដុល្លារអាមេរិកនៅឆ្នាំ២០១៩, ហ៊ុល រស្មី, 05 តុលា 2018, https://khmer.voanews.com/a/cambodia-set-a-new-minimum-wage-for-garment-workers-in-2019/4601462.html

[45] https://vodkhmer.news/2019/09/20/190920-vod-kun-f-labor-mininum-wage-for-workers-reache-190usd-in-2020/

ន៍ផងដែរ។[46] ប៉ុន្តែច្បាប់នេះត្រូវបានទទួលរងការរិះគន់ថា មិនបានឆ្លងកាត់ការពិគ្រោះយោបល់ឲ្យបានទូលំទូលាយពីភាគីពាក់ព័ន្ធជាពិសេសអង្គការសង្គមស៊ីវិល និងសហជីពដែលធ្វើកំពុងធ្វើការតាមដាន និងឃ្លាំមើលសិទ្ធិសេរីភាព និងការពារអត្ថប្រយោជន៍របស់កម្មករ។ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) កន្លងមកបាន និងកំពុងអនុវត្តនូវរបបសន្តិសុខសង្គមចំនួន ២ គឺផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពដែលចាប់តាំង ពីឆ្នាំ ២០១៩ មករបបសន្តិសុខសង្គមទាំងពីរនេះ បានគ្របដណ្តប់ទាំងកម្មករនិយោជិត និងមន្ត្រីសាធារណៈ។

ទោះបីជាមានភាពប្រសើរឡើងមួយចំនួននៅក្នុងវិស័យសិទ្ធ និងការងារកម្មករយ៉ាងណាហើយក្តីក៏វិស័យនេះកំពុងបានប្រឈម និងភាពមិនច្បាស់លាស់មួយចំនួននៅពេលអនាគតក្នុការធ្វើពាណិជ្ជកម្ម ដែលអាចនឹងបណ្តាលមកពីស្ថានការនយោបាយក្នុងប្រទេសផង រួមនិងការវិវត្តន៏នៃនយោបាយនៅក្នុងតំបន់ទាក់ទិនទៅនឹងភូមិសាស្រ្តនយោបាយរបស់មហាអំណាចផងដែរ និងការវិត្តន៏របស់សេដ្ឋកិច្ចក្នុងពិភពលោកផងដែរ[47]។

## VIII. ការផ្តល់ពិន្ទុលើការអនុវត្តគោលការណ៍អភិបាលកិច្ចល្អនៅមូលដ្ឋានឃុំ/សង្កាត់

ក្រុមប្រឹក្សាឃុំ/សង្កាត់បានអនុវត្តជាមន្ត្រីជាប់ឆ្នោតចំនួន ៣ឆ្នាំរួចមកហើយចាប់តាំងពីការបោះឆ្នោតឆ្នាំ ២០១៧មក។ រចនាសម្ព័នដឹកនាំថ្នាក់មូលដ្ឋានត្រូវបានបោះឆ្នោតជ្រើសរើសជាសកលដោយប្រជាពលរដ្ឋដែលបានចេញទៅបោះឆ្នោតសរុបចំនួន ៧,១០៧,៣៩៥នាក់ស្មើនឹង ៩០.៣៧ភាគរយដែលបានបោះឆ្នោត។ ក្រុមប្រឹក្សាឃុំ/សង្កាត់ត្រូវមានទំនួលខុសត្រូវខ្ពស់ចំពោះប្រជាពលរដ្ឋក្នុងឃុំ/សង្កាត់របស់ខ្លួន។ **ប្រព័ន្ធអភិបាលកិច្ចមូលដ្ឋានត្រូវអនុវត្តនៅថ្នាក់ឃុំសង្កាត់** យោងមាត្រា០៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់។ ហើយមាត្រា៤១ នៃច្បាប់នេះដដែលបានបញ្ជាក់ថា រដ្ឋបាលឃុំ/សង្កាត់មានតួនាទីជំរុញ និងគាំពារអភិបាលកិច្ចល្អ។ រដ្ឋបាលឃុំ/សង្កាត់មានតួនាទីពីរប្រភេទគឺ៖ ទី១ គឺតួនាទីបំរើកិច្ចការមូលដ្ឋានសម្រាប់បម្រើផលប្រយោជន៍ឃុំ/សង្កាត់ និងប្រជាពលរដ្ឋក្នុងឃុំ/សង្កាត់របស់ខ្លួន។ និងទី២ គឺតួនាទីជាភ្នាក់ងារតំណាងរដ្ឋ ក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ។

---

[46] ឯកឧត្តមបណ្ឌិត អុ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវ: បានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះ លទ្ធផលការងារដែល ប.ស.ស សម្រេចបានក្នុងឆ្នាំ២០១៩ កន្លងមកនេះ ដោយ៖ Roeun Setharun, ចេញផ្សាយ៖ ថ្ងៃ សុក្រ ទី ១៧ ខែ មករា ឆ្នាំ ២០២០, https://bit.ly/35w8sP3

[47] Khmer Times: **Cambodia's exports continue to face challenges amidst global headwinds, September 18, 2020, bySorn Sarath; https://www.khmertimeskh.com/50764362/cambodias-exports-continue-to-face-challenges-amidst-global-headwinds/**

ក្នុងតួនាទីបំរើកិច្ចការមូលដ្ឋាន រដ្ឋបាលឃុំសង្កាត់មានភារកិច្ចចំបងៗដូចជា៖ ការធានារក្សាសន្តិសុខសណ្តាប់ធ្នាប់ ការរៀបចំចាត់ចែងសាវាសាធារណៈចាំបាច់ ការលើកទឹកចិត្តឲ្យមានការបង្កើនផាសុកភាព និងសុខុមាលភាព ការជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងលើកកម្ពស់ជីវភាពរបស់នៅប្រជាពលរដ្ឋ ការការពារថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ ការសម្របសម្រួលទស្សនៈរបស់ប្រជាពលរដ្ឋ និងការបំពេញកិច្ចការងារទូទៅដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។

អនុលោមមាត្រា០៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ ដើម្បីឲ្យតួនាទី និងភារកិច្ចខាងលើសម្រេចបាន ក្រុមប្រឹក្សាឃុំ/សង្កាត់ត្រូវប្រកាន់ភ្ជាប់នូវគោលការណ៍អភិបាលកិច្ចល្អ មានដូចជា៖**ការចូលរួមរបស់ប្រជាពលរដ្ឋ, នីតិរដ្ឋ នៅក្នុងឃុំសង្កាត់, តម្លាភាព, ការព្រមព្រៀងឯកភាពគ្នា, សមធម៌, ប្រសិទ្ធភាពខ្ពស់, គណនេយ្យភាព, និងការឆ្លើយតប។**

វេទិកាប្រជាពលរដ្ឋនៅថ្នាក់ឃុំ/សង្កាត់នេះ បានរៀបចំជាលើកដំបូងក្នុងឆ្នាំ២០២០នេះ ចំនួន៦កន្លែង នៅក្នុងឃុំសង្កាត់ចំនួន០៦ នៃខេត្តចំនួន០៦ ដូចជា៖ ខេត្តបន្ទាយមានជ័យ ព្រៃវែង សៀមរាប កំពង់ឆ្នាំង កំពត និងខេត្តក្រចេះ។ វេទិកានេះ មានប្រជាពលរដ្ឋចូលរួមសរុបចំនួន ១៨០នាក់ (៦៨% ជាស្ត្រី) និងតំណាងក្រុមប្រឹក្សាឃុំ/សង្កាត់ ដែលជាចៅសង្កាត់រង/ជំទប់ឃុំ ចំនួន១១នាក់បានចូលរួមផងដែរ។ការពិភាក្សា និងផ្តល់ពិន្ទុ គឺបានប្រើប្រាស់ឯកសារគោលជាមូលដ្ឋានដែលផលិតដោយក្រសួងមហាផ្ទៃ“អភិបាលកិច្ចល្អសម្រាប់ក្រុមប្រឹក្សាឃុំសង្កាត់”។

## ក. ការផ្តល់ចំណេះដឹងដល់ប្រជាពលរដ្ឋពីគោលការណ៍អភិបាលកិច្ចល្អ

ក្នុងវេទិកាថ្នាក់ឃុំសង្កាត់នេះ មានប្រជាពលរដ្ឋចំនួន ១៨០នាក់បានចូលរួម និងមកពីស្ទើគ្រប់ភូមិក្នុងឃុំសង្កាត់។ ខុមហ្វ្រែល បានរៀបចំជាមេរៀនស្តីពី គោលការណ៍អភិបាលកិច្ចល្អ ដែលក្នុងមេរៀនបានបង្ហាញពីអ្វីដែលជាតួនាទីប្រជាពលរដ្ឋត្រូវចូលរួម ហើយអ្វីដែលក្រុមប្រឹក្សាឃុំសង្កាត់ត្រូវដោះស្រាយ និងការរៀបចំផែនការ។ ចំណេះដឹងនេះមិនត្រូវបានធ្វើជាការសាកសល្បងចំណេះដឹងមុន ឬក្រោយចគ្គនោះទេ តែប្រជាពលរដ្ឋ និងសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ដែលបានចូលរួម បានអបអរសាទរពីបទបង្ហាញនេះថា មានសារៈសំខាន់មួយ ក្នុងការយល់ដឹងរបស់ពួកគេ រួមទាំងជម្រុញឱ្យពួកគេចូលរួមតាមដានដំណើរការអភិវឌ្ឍន៍ឃុំសង្កាត់ទៀតផង។

បុរសម្នាក់ដែលបានចូលរួមយ៉ាងសកម្មនៅក្នុងវេទិកានៅឯខេត្តព្រៃវែងបាននិយាយបន្ទាប់ពីកម្មវិធី នោះថាគាត់ពិតជារីករាយដែលបានចូលរួមក្នុងវេទិកានេះពីព្រោះគាត់បានដឹងកាន់តែច្បាស់អំពីគោលការណ៍អភិបាលកិច្ចល្អក្នុងឃុំ/សង្កាត់ ហើយការយល់ដឹងនេះនឹងជួយគាត់ក្នុងការឃ្លាំមើលការអភិវឌ្ឍនៅក្នុងឃុំរបស់ពួកគេ។ គាត់ក៏ប្តេជ្ញាចែករំលែកអ្វីដែលគាត់បានរៀនពីវេទិកាដល់មនុស្សផ្សេងទៀត។ អនុប្រធានទី ២ នៃឃុំរកាកណ្តាលក្នុងខេត្តក្រចេះបានបញ្ជាក់ថាវេទិកានេះគឺដើម្បីរំលឹក ក្រុមប្រឹក្សាឃុំឱ្យអនុវត្តតួនាទីនិងទំនួលខុសត្រូវរបស់ខ្លួនឲ្យកាន់តែប្រសើរ។



## ខ. ការពិភាក្សារវាងប្រជាពលរដ្ឋ និងក្រុមប្រឹក្សាឃុំសង្កាត់

ផ្អែកលើគោលបំណងនៃវេទិកា ការជជែករបស់ប្រជាពលរដ្ឋក្នុងវេទិកាជាមួយក្រុមប្រឹក្សាឃុំសង្កាត់ ខុមប្រៀលបានកំណត់បញ្ហាប្រឈមធំៗ ចំនួន០៤ ត្រូវបានលើកឡើងក្នុងវេទិកាដោយផ្ទាល់ពីប្រជាពលរដ្ឋ និងត្រូវការស្វែងរកដំណោះស្រាយពីក្រុមប្រឹក្សាឃុំសង្កាត់ មានដូចជា៖

- សុំឱ្យមានការចូលរួមពីប្រជាពលរដ្ឋ ជាពិសេសយុវជនក្នុងដំណើរការកសាងផែនការអភិវឌ្ឍនានា
- ការរក្សាសណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាពចរាចរណ៍ និងសុវត្ថិភាពនៅមូលដ្ឋានភូមិ/ឃុំ
- ស្នើឱ្យ អាជ្ញាធរយកចិត្តទុកដាក់លើបញ្ហា ក្នុងមូលដ្ឋានដូចជា សាលារៀន ផ្សារ និងសិទ្ធិរបស់កុមារ
- បង្កើនការយកចិត្តទុកដាក់លើភាពអសកម្មរបស់អាជ្ញាធរមូលដ្ឋានក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋ

ក្នុងវេទិកា ក្រុមប្រឹក្សាឃុំសង្កាត់ដែលបានចូលរួមបានដោះស្រាយភ្លាមនូវចំណុចមួយចំនួន ដែលអាចដោះស្រាយបាន និងចំណុចខ្លះបានដាក់ជាផែនការក្នុងការដោះស្រាយបន្ត។ ចំណុចដែលក្រុមប្រឹក្សាឃុំសង្កាត់បានដោះស្រាយជូនប្រជាពលរដ្ឋភ្លាម មានដូចជាករណីស្នើសុំការសហការពីប្រជាពលរដ្ឋដើម្បីដោះស្រាយបញ្ហាសិទ្ធិកុមារ និងសាលារៀន និងបញ្ហាភូមិឃុំមានសុវត្ថិភាពនៅក្នុងឃុំ/សង្កាត់។ ករណីដែលអាជ្ញាធរមិនអាចដោះស្រាយបានជូនប្រជាពលរដ្ឋមានដូចជា ករណីការស្នើសុំបង្កើតផ្សារ ឬហេដ្ឋារចនាសម្ព័នផ្លូវថ្នល់ជាដើមព្រោះបញ្ហាទាំងអស់នោះត្រូវបញ្ចូលក្នុងផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់ប្រចាំឆ្នាំ។

## គ. ការវាយតម្លៃដំណើរការអភិបាលកិច្ចល្អដោយផ្ដល់ពិន្ទុ

ប្រជាពលរដ្ឋដែលចូលរួមក្នុងវេទិកាក៏បានចូលរួមផងដែរក្នុងការផ្ដល់ពិន្ទុវាយតម្លៃលើការពេញចិត្តឬមិនពេញចិត្តរបស់ខ្លួន ចំពោះការអនុវត្តគោលការណ៍អភិបាលកិច្ចល្អទាំង៨ចំណុច ដូចខាងក្រោម៖

- គោលការណ៍ទី១៖ ការចូលរួមរបស់ប្រជាពលរដ្ឋ
- គោលការណ៍ទី២៖ នីតិរដ្ឋ នៅក្នុងឃុំសង្កាត់
- គោលការណ៍ទី៣៖ តម្លាភាព
- គោលការណ៍ទី៤៖ ការព្រមព្រៀងឯកភាពគ្នា
- គោលការណ៍ទី៥៖ សមធម៌
- គោលការណ៍ទី៦៖ ប្រសិទ្ធភាពខ្ពស់
- គោលការណ៍ទី៧៖ គណនេយ្យភាព
- គោលការណ៍ទី៨៖ ការឆ្លើយតប

**មធ្យមភាគនៃគោលការណ៍ទាំង៨ ដែលប្រជាពលរដ្ឋបានដាក់ពន្ទុ៖**

| ការអនុវត្តគោលកាណ៍ | មិនពេញចិត្ត(%) | ពេញចិត្តខ្លះ(%) | ពេញចិត្តមធ្យម (%) | ពេញចិត្តច្រើន (%) | ពេញចិត្តទាំងស្រុង (%) | ពិន្ទុមធ្យម (#/5) |
|---|---|---|---|---|---|---|
| គោលការណ៍ទី១៖ ការចូលរួមរបស់ប្រជាពលរដ្ឋ | 1.96 | 11.30 | 21.83 | 33.90 | 31.02 | 3.81 |
| គោលការណ៍ទី២៖ នីតិរដ្ឋ នៅក្នុងឃុំសង្កាត់ | 2.54 | 8.67 | 20.95 | 33.62 | 34.21 | 3.89 |
| គោលការណ៍ទី៣៖ តម្លាភាព | 2.87 | 7.45 | 30.29 | 31.45 | 27.94 | 3.74 |
| គោលការណ៍ទី៤៖ ការព្រមព្រៀងឯកភាពគ្នា | 2.58 | 7.74 | 26.70 | 40.86 | 22.12 | 3.72 |
| គោលការណ៍ទី៥៖ សមធម៌ | 1.85 | 7.65 | 25.27 | 38.19 | 27.05 | 3.81 |
| គោលការណ៍ទី៦៖ ប្រសិទ្ធភាពខ្ពស់ | 2.25 | 11.08 | 30.21 | 31.75 | 24.71 | 3.66 |
| គោលការណ៍ទី៧៖ គណនេយ្យភាព | 2.69 | 11.02 | 22.36 | 34.08 | 29.85 | 3.77 |
| គោលការណ៍ទី៨៖ ការឆ្លើយតប | 2.55 | 8.38 | 19.31 | 28.96 | 40.80 | 3.97 |
| លទ្ធផលមធ្យមទាំង០៨គោលការណ៍ | 2.41 | 9.16 | 24.62 | 34.10 | 29.71 | 3.80 |

តារាងខាងលើបានបង្ហាញថា ប្រជាពលរដ្ឋបានពេញចិត្តលើគោលការណ៍ទាំង៨ នៃគោលការណ៍អភិបាលកិច្ចល្អ ក្នុងកម្រិតចន្លោះ ពេញចិត្តមធ្យម ទៅពេញចិត្តច្រើន (លេខពិន្ទុ ៣.៨) ឬក្នុងចន្លោះពី៤១ភាគរយទៅ ៨០ភាគរយ។

ចំណុចទាំង៨ នៃគោលការណ៍នេះ មានចំណុចពីរដែលប្រជាពលរដ្ឋពេញចិត្តខ្ពស់ជាងគេគឺ គោលការណ៍ទី២ ចែងពីនីតិរដ្ឋ នៅក្នុងឃុំសង្កាត់ និងគោលការណ៍ទី៨ លើការឆ្លើយតប។

## ក្រាហ្វិកអំពីភាគរយជាមធ្យមនៃការវាយតម្លៃលើចំណុចទាំង៨




តាមលទ្ធផល បង្ហាញថា ពលរដ្ឋដែលបានចូលរួមវាយតម្លៃនៃដំណើរការអនុវត្តគោលការណ៍អភិបាលកិច្ចល្អនៅមូលដ្ឋានឃុំសង្កាត់ចំនួនរហូតដល់ ៣៤.១ភាគរយ **ពេញចិត្តច្រើន** ចំពោះលទ្ធផលនៃការអនុវត្តគោលការណ៍នៅមូលដ្ឋានឃុំ/សង្កាត់។ ២៩.៧១ភាគរយពេញចិត្តទាំងស្រុងនៃការអនុវត្តគោលការទាំង៨ នេះ។

ដោយផ្អែកទៅលើរបបគំហើញនេះ អ្នកចូលរួមបានអោយតម្លៃខ្ពស់ (ពិន្ទុ៣.៨០/៥) លើសមត្ថភាពរបស់អភិបាលកិច្ចមូលដ្ឋានក្នុងការឆ្លើយជាមួយប្រជាពលរដ្ឋរបស់ខ្លួន។ ការរកឃើញនេះប៉ាក់ដូចបានឆ្លុះបញ្ចាំងលើការអនុវត្តន៏ជាក់ស្តែងផងដែរ ដោយសារតែពួកគាត់ជាញឹកញាប់តែងទទួលបាននូវការណែរនាំពីថ្នាក់លើដើម្បីអោយមានឆ្លើយតបអោយបានទាន់ពេលវេលាចំពោះរាលើកង្វល់និងតម្រូវការរបស់ពលរដ្ឋនៅក្នុមូលដ្ឋាន។ តែដោយឡែក «ប្រសិទ្ធិភាព» នៃការបំពេញការងារត្រូវបានគេផ្តល់ពិន្ទុទាបជាងគេនៅក្នុងចំណោមគោលការណ៍ទាំង៨នៅក្នុងតារាង។ ពលរដ្ឋអ្នកចូលរួមក៏បានផ្តល់តម្លៃខ្ពស់ លើការបង្ករលក្ខណះអោយមានការចូលរួមពីពលរដ្ឋនៅក្នុងមូលដ្ឋានឃុំសង្កាត់ដែលមានពិន្ទុ ៣.៨១/៥។

លទ្ធផលខាងលើក៏បានបង្ហាញផងដែរថា មានប្រជាពលរដ្ឋប្រមាណ១១%មិនពេញចិត្ត និងពេញចិត្តខ្លះ និងបប្រមាណ២៤% ពេញចិត្តមធ្យម ចំពោះលទ្ធផលនៃការអនុវត្តគោលការណ៍ខាងលើផងដែរ។

តាមរយៈលទ្ធផលខាងលើ ការអនុវត្តគោលការណ៍អភិបាលកិច្ចល្អនៅមូលដ្ឋានឃុំ/សង្កាត់ត្រូវបានប្រជាពលរដ្ឋគាំទ្រ និងបង្ហាញការពេញចិត្តជាពិសេសទៅលើលទ្ធភាពនៃការឆ្លើយតបនឹងបញ្ហា ឬកង្វល់របស់ពលរដ្ឋហើយ និងការបង្ករលក្ខណៈអោយមានការចូលរួមពីពលរដ្ឋនៅក្នុមូលដ្ឋាន។– ទោះជាយ៉ាងណា តាមរយះរបបគំហើញនេះអាជ្ញាធរឃុំ/សង្កាត់ត្រូវតែបន្តការខិតខំប្រឹងប្រែងក្នុងការអនុវត្តគោលការណ៍ទាំង០៨នៃអភិបាលកិច្ចល្អមូលដ្ឋានឃុំ/សង្កាត់ប្រកបដោយប្រសិទ្ធិភាពខ្ពស់ ដើម្បីបន្តទទួលបានការពេញចិត្តពីប្រជាពលរដ្ឋបន្ថែមទៀត។

## IX. សេចក្តីសន្និដ្ឋាន

រាជរដ្ឋាភិបាលក្នុងនីតិកាលទី៦ បានកើតចេញពីលទ្ធផលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ២០១៨ ។ គិតត្រឹមឆ្នាំ២០២០ រាជរដ្ឋាភិបាលនីតិកាលទី៦នេះ មានសមាជិកចំនួន ៤៧ រូប ជាសមាជិកគណៈរដ្ឋមន្ត្រី។ មន្ត្រីជាន់ខ្ពស់យ៉ាងហោចណាស់ចំនួន ៩០១ រូប ដែលក្នុងនោះជារដ្ឋលេខាធិការចំនួន ២៦០ រូប អនុរដ្ឋលេខាធិការ ចំនួន ៤១៥ រូប រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ចំនួន ១៩រូប និងទីប្រឹក្សារដ្ឋាភិបាល ២០៧ រូប។ រដ្ឋាភិបាលមានគោលនយោបាយធ្វើកំណែទម្រង់អភិបាលកិច្ចល្អក្នុងស្ថាប័នសាធារណៈ ដែលធ្វើឱ្យ កើនឡើងនៃចំនួនមន្ត្រីជាន់ខ្ពស់ តែមិនអាចបង្ហាញអំពីប្រសិទ្ធភាពនៃកំណែទម្រង់បានឡើយ។

ឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ ដែលបានបង្កើតថ្មី និងត្រូវបានចាត់ទុកថាជាយន្តការក្រៅសភាដែលទទួលធាតុចូលបន្ថែមពីគណបក្សនយោបាយ មិនមានឯករាជ្យពេញលេញក្នុងការបំពេញភារកិច្ចរបស់ខ្លួនដូចអ្នកតំណាងរាស្ត្រដែលប្រជាពលរដ្ឋបោះឆ្នោត និងផ្តល់អំណាចឱ្យនោះឡើយ។

គោលនយោបាយ និងកិច្ចការងារជាអាទិភាពរបស់រាជរដ្ឋាភិបាលដែលបានថែង ឬសន្យា តាមរយៈយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ អំពីការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ចល្អ មិនបានកំណត់នូវសូចនាករច្បាស់លាស់ដើម្បីវាស់វែងពីសមិទ្ធិផលនោះទេ។

រាជរដ្ឋាភិបាល ក្នុងឆ្នាំទី២នៃការអនុវត្តគោលនយោនបាយរបស់ខ្លួន បានគ្រោងចំណាយថវិកាថ្នាក់ជាតិ ប្រមាណ ៧.៧៧៣,៩៦ លានដុល្លារអាមេរិក។ ថវិកាចំណាយថ្នាក់ជាតិ បានធ្លាក់ចុះ លើ លើវិស័យសង្គម និងសេដ្ឋកិច្ច បើប្រៀបធៀបនឹងឆ្នាំ២០១៩។ ប៉ុន្តែផ្ទុយពីឆ្នាំមុនៗ រាជរដ្ឋាភិបាលបានគ្រោងថវិកាចំណាយមិនទាន់បែងចែករហូតដល់២៧%នៃថវិកាចំណាយថ្នាក់ជាតិសរុប ស្របពេលដែលកាលឆ្នាំ២០១៩ រដ្ឋាភិបាលបានគ្រោងខ្ទង់ចំណាយនេះត្រឹមតែ១៩%តែប៉ុណ្ណោះ។

ដោយឡែកសម្រាប់ការអនុវត្តគោលការណ៍អភិបាលកិច្ចល្អដើម្បីអភិវឌ្ឍន៍មូលដ្ឋានឃុំ/សង្កាត់ត្រូវបានប្រជាពលរដ្ឋដែលបានចូលរួមវាយតម្លៃលើការពេញចិត្តចំនួន (ចំនួន ៣៤% **ពេញចិត្តច្រើន** និងប្រមាណ ២៤% ទៀតមានការ**ពេញចិត្តមធ្យម**)។ ជាមួយគ្នានេះ ប្រជាពលរដ្ឋចំនួនដែលបាន បានសម្តែងការមិនពេញចិត្ត និងពេញចិត្តខ្លះមានចំនួនប្រមាណ១១%ចំពោះលទ្ធផលនៃការអនុវត្តគោលការណ៍ទាំងនេះនៅមូលដ្ឋានឃុំ/សង្កាត់។ បើពិនិត្យមើលពិន្ទុជាមធ្យមដែលប្រជាពលរដ្ឋបានដាក់ចំពោះលទ្ធផលនៃការអនុវត្តគោលការណ៍ទាំងនេះវិញគឺ ៣.៨នៃពិន្ទុ៥។ តាមរយៈលទ្ធផលដែលបានបង្ហាញដោយពលរដ្ឋដែលបានចូលរួមក្នុងវេទិកាខាងលើ ការអនុវត្តគោលការណ៍អភិបាលកិច្ចល្អនៅមូលដ្ឋានឃុំ/សង្កាត់ត្រូវបានប្រជាពលរដ្ឋគាំទ្រ និងបង្ហាញការពេញចិត្តជាពិសេសទៅលើលទ្ធភាពនៃការឆ្លើយតប នឹងបញ្ហា ឬកង្វល់របស់ពលរដ្ឋហើយនិងការបង្ករលក្ខណៈអោយមានការចូលរួមពីពលរដ្ឋនៅ ក្នុងមូលដ្ឋានប៉ុន្តែពួកគាត់ក៏បានបង្ហាញអោយឃើញថាគាត់មានការខកចិត្តខ្លាំងនៅឡើយលើការខ្វះនូវគណនីយភាពនិងតម្លាភាពក្នុងមូលដ្ឋានផងដែរ។ ដូចនេះ

តាមរយៈរបបគំហើញនេះអាជ្ញាធរឃុំ/សង្កាត់ ត្រូវតែបន្តការខិតខំប្រឹងប្រែងក្នុងការអនុវត្តគោលការណ៍ទាំង ០៨នៃអភិបាលកិច្ចល្អមូលដ្ឋានឃុំ/សង្កាត់ប្រកបដោយប្រសិទ្ធិភាពខ្ពស់ ដើម្បីបន្តទទួលបានការពេញចិត្តពីប្រជាពលរដ្ឋបន្ថែមទៀត។

## x. ផ្នែកឧបសម្ព័ន

## លក្ខខណ្ឌនៃការវាយតម្លៃ និងផ្តល់ពិន្ទុ

| លក្ខខណ្ឌការវាយតម្លៃ | | | | | |
|---|---|---|---|---|---|
| មិនពេញចិត្ត<br>០-២០% (១) | ពេញចិត្តខ្លះ<br>២១%-៤០% (២) | ពេញចិត្តមធ្យម<br>៤១%-៦០% (៣) | ពេញចិត្តច្រើន<br>៦១%-៨០% (៤) | ពេញចិត្តទាំងស្រុង<br>៨១%-១០០% (៥) | មិនវាយតម្លៃ |

## ព័ត៌មាននៃអ្នកចូលរួមផ្តល់ពិន្ទុ

| | ចំនួននៃអ្នកចូលរួមផ្តល់ពិន្ទុ និងផ្តល់ចម្លើយ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ភេទ | | អាយុ | | កម្រិតវប្បធម៌ | | ក្រុមប្រឹក្សាឃុំ/សង្កាត់ជា......... | | ក្រុមប្រឹក្សាឃុំ/សង្កាត់មានតួនាទីជា........ (អ្នកចូលរួមជ្រើសរើសចម្លើយច្រើន) | |
| ០៦ ឃុំ/សង្កាត់ នៃ ០៦ ខេត្ត | ប្រុស | 60 | ១៨-៣០ | 48 | 1.បឋមសិក្សា | 51 | ១. ជាមន្ត្រីរាជការ | 4 | ១. ធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់របៀបរៀបរយសាធារណ: | 86 |
| | ស្រី | 106 | ៣១-៤៥ | 44 | 2.មធ្យមសិក្សាកំរិត១ | 60 | ២. ជាអ្នកមានលុយ | 2 | ២. លើកទឹកចិត្ត ឱ្យមានការបង្កើនផាសុខភាព និងសុខមាលភាពរបស់ប្រជាពលរដ | 96 |
| | មិនផ្តល់ចម្លើយ | 3 | ៤៦-៦០ | 48 | 3.មធ្យមសិក្សាកំរិត២ | 36 | ៣. មិនដឹង | 2 | ៣. អ្នកការពារ ថែរក្សាបរិស្ថាន និងធនធានធម្មជាត | 81 |
| | | | ៦០ ឡើង | 23 | 4.ឧត្តមសិក្សា | 9 | ៤. ជាអ្នក ជាប់ឆ្នោត ត្រូវបាន | 157 | ៤. បំពេញកិច្ចការជាទូទៅឆ្លើយតបតម្រូវការ របស់ប្រជាពលរដ | 124 |
| | | | មិនផ្តល់ចម្លើយ | 6 | 5.អនុបណ្ឌិត | 1 | ៥. ជាស្មៀនឃុំសង្កាត់ | 3 | ៥. អនុវត្តកិច្ចការអត្រានុកូលដ្ឋាន និងកិច្ចការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះអ្នកបោះឆ្នោត | 128 |
| | | | | | ផ្សេងទៀត | 6 | ៦. ជាមន្ត្រីប៉ូលីស ទាហាន | 0 | ៦. ចាត់ចែងសេវាសាធារណ:មូលដ្ឋាន | 92 |
| | | | | | មិនផ្តល់ចម្លើយ | 6 | មិនជ្រើសរើសចម្លើយ | 1 | ៧. ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងលើកកំពស់ជីវភាពរស់នៅរបស់អ្នកភូម | 114 |
| | | | | | | | | | ៨. សំរបសំរួលទស្សនៈរបស់ប្រជាពលរដ្ឋឲ្យមានការយោគយល់គ្នាទៅវិញទៅមក | 98 |
| | | | | | | | | | ៩. អនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន | 92 |

## លទ្ធផលវាយតម្លៃតាមឃុំ/សង្កាត់

- លទ្ធផលវាយតម្លៃនៅសង្កាត់រកាកណ្តាល ក្រុងក្រចេះ ខេត្តក្រចេះ

| | **ចំនួននៃអ្នកចូលរួមផ្តល់ពិន្ទុ និងផ្តល់ចម្លើយ** | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ភេទ | | អាយុ | | កម្រិតវប្បធម៌ | | ក្រុមប្រឹក្សាឃុំ/សង្កាត់ជា......... | | ក្រុមប្រឹក្សាឃុំ/សង្កាត់មានតួនាទីជា........ (អ្នកចូលរួមជ្រើសរើសចម្លើយច្រើន) | |
| **ខេត្តក្រចេះ** | ប្រុស | 8 | ១៨-៣០ | 9 | 1.បឋមសិក្សា | 5 | ១. ជាមន្ត្រីរាជការ | 3 | ១. ធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់របៀបរៀបរយសាធារណ: | 15 |
| | ស្រី | 21 | ៣១-៤៥ | 5 | 2.មធ្យមសិក្សាកំរិត១ | 13 | ២. ជាអ្នកមានលុយ | 0 | ២. លើកទឹកចិត្ត ឱ្យមានការបង្កើនផាសុខភាព និងសុខមាលភាពរបស់ប្រជាពលរដ | 11 |
| | មិនផ្តល់ចម្លើយ | 0 | ៤៦-៦០ | 6 | 3.មធ្យមសិក្សាកំរិត២ | 7 | ៣. មិនដឹង | 1 | ៣. អ្នកការពារ ថែរក្សាបរិស្ថាន និងធនធានធម្មជាត | 9 |
| | | | ៦០ ឡើង | 9 | 4.ឧត្តមសិក្សា | 0 | ៤. ជាអ្នក ជាប់ឆ្នោត ត្រូវបាន | 25 | ៤. បំពេញកិច្ចការជាទូទៅឆ្លើយតបតម្រូវការ របស់ប្រជាពលរដ | 13 |
| | | | មិនផ្តល់ចម្លើយ | 0 | 5.អនុបណ្ឌិត | 0 | ៥. ជាស្មៀនឃុំសង្កាត់ | 0 | ៥. អនុវត្តកិច្ចការអត្រានុកូលដ្ឋាន និង កិច្ចការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះអ្នកបោះឆ្នោត | 21 |
| | | | | | ផ្សេងទៀត | 4 | ៦. ជាមន្ត្រីប៉ូលីស ទាហាន | 0 | ៦. ចាត់ចែងសេវាសាធារណ:មូលដ្ឋាន | 8 |
| | | | | | មិនផ្តល់ចម្លើយ | 0 | មិនជ្រើសរើសចម្លើយ | 0 | ៧. ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងលើកកំពស់ជីវភាពរស់នៅរបស់អ្នកភូម | 11 |
| | | | | | | | | | ៨. សំរបសំរួលទស្សនៈរបស់ប្រជាពលរដ្ឋឲ្យមានការយោគយល់គ្នាទៅវិញទៅមក | 10 |
| | | | | | | | | | ៩. អនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន | 10 |

| **ការអនុវត្តគោលកាណ៍** | មិនពេញចិត្ត(%) | ពេញចិត្តខ្លះ(%) | ពេញចិត្តមធ្យម(%) | ពេញចិត្តច្រើន (%) | ពេញចិត្តទាំងស្រុង (%) | ពិន្ទុមធ្យម នៃ(#/5) |
|---|---|---|---|---|---|---|
| គោលការណ៍ទី១៖ ការចូលរួមរបស់ប្រជាពលរដ្ឋ | 0.00 | 7.07 | 22.52 | 25.63 | 44.79 | 4.08 |
| គោលការណ៍ទី២៖ នីតិរដ្ឋ នៅក្នុងឃុំសង្កាត់ | 0.00 | 1.72 | 26.72 | 29.31 | 42.24 | 4.14 |
| គោលការណ៍ទី៣៖ តម្លាភាព | 0.00 | 5.23 | 35.10 | 31.59 | 28.08 | 3.83 |

| | | | | | | |
|---|---|---|---|---|---|---|
| គោលការណ៍ទី៤៖ ការព្រមព្រៀងឯកភាពគ្នា | 0.00 | 3.45 | 34.48 | 37.93 | 24.14 | 3.83 |
| គោលការណ៍ទី៥៖ សមធម៌ | 0.00 | 3.45 | 27.59 | 37.93 | 31.03 | 3.97 |
| គោលការណ៍ទី៦៖ ប្រសិទ្ធភាពខ្ពស់ | 0.60 | 5.36 | 41.07 | 28.57 | 24.40 | 3.71 |
| គោលការណ៍ទី៧៖ គណនេយ្យភាព | 0.00 | 0.00 | 32.14 | 17.86 | 50.00 | 4.18 |
| គោលការណ៍ទី៨៖ ការឆ្លើយតប | 0.00 | 7.14 | 28.57 | 28.57 | 35.71 | 3.93 |
| លទ្ធផលមធ្យមទាំង០៨គោលការណ៍ | 0.07 | 4.18 | 31.02 | 29.67 | 35.05 | 3.96 |

- លទ្ធផលវាយតម្លៃនៅ ឃុំអញ្ចាញរូង ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង

| | ចំនួននៃអ្នកចូលរួមផ្តល់ពិន្ទុ និងផ្តល់ចម្លើយ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ភេទ | | អាយុ | | កម្រិតវប្បធម៌ | | ក្រុមប្រឹក្សាឃុំ/សង្កាត់ជា......... | | ក្រុមប្រឹក្សាឃុំ/សង្កាត់មានតួនាទីជា........ (អ្នកចូលរួមជ្រើសរើសចម្លើយច្រើន) | |
| ខេត្តកំពង់ឆ្នាំង | ប្រុស | 1 | ១៨-៣០ | 8 | 1.បឋមសិក្សា | 9 | ១. ជាមន្រ្តីរាជការ | 0 | ១. ធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ | 11 |
| | ស្រី | 31 | ៣១-៤៥ | 13 | 2.មធ្យមសិក្សាកំរិត១ | 11 | ២. ជាអ្នកមានលុយ | 1 | ២. លើកទឹកចិត្ត ឱ្យមានការបង្កើនផាសុខភាព និងសុខមាលភាពរបស់ប្រជាពលរដ | 19 |
| | មិនផ្តល់ចម្លើយ | 0 | ៤៦-៦០ | 8 | 3.មធ្យមសិក្សាកំរិត២ | 8 | ៣. មិនដឹង | 0 | ៣. អ្នកការពារ ថែរក្សាបរិស្ថាន និងធនធានធម្មជាត | 20 |
| | | | ៦០ ឡើង | 1 | 4.ឧត្តមសិក្សា | 0 | ៤. ជាអ្នក ជាប់ឆ្នោត ត្រូវបាន | 30 | ៤. បំពេញកិច្ចការជាទូទៅឆ្លើយតបតម្រូវការ របស់ប្រជាពលរដ | 21 |
| | | | មិនផ្តល់ចម្លើយ | 2 | 5.អនុបណ្ឌិត | 1 | ៥. ជាស្មៀនឃុំសង្កាត់ | 1 | ៥. អនុវត្តកិច្ចការអត្រានុកូលដ្ឋាន និង កិច្ចការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះអ្នកបោះឆ្នោត | 24 |
| | | | | | ផ្សេងទៀត | 1 | ៦. ជាមន្រ្តីប៉ូលីស ទាហាន | 0 | ៦. ចាត់ចែងសេវាសាធារណៈមូលដ្ឋាន | 20 |
| | | | | | មិនផ្តល់ចម្លើយ | 2 | មិនជ្រើសរើសចម្លើយ | 0 | ៧. ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងលើកកំពស់ជីវភាពរស់នៅរបស់អ្នកភូមិ | 23 |
| | | | | | | | | | ៨. សំរបសំរួលទស្សនៈរបស់ប្រជាពលរដ្ឋឲ្យមានការយោគយល់គ្នាទៅវិញទៅមក | 13 |
| | | | | | | | | | ៩. អនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន | 20 |

| **ការអនុវត្តគោលកាណ៌** | មិនពេញចិត្ត(%) | ពេញចិត្តខ្លះ(%) | ពេញចិត្តមធ្យម(%) | ពេញចិត្តច្រើន (%) | ពេញចិត្តទាំងស្រុង (%) | ពិន្ទុមធ្យម (#/5) |
|---|---|---|---|---|---|---|
| គោលការណ៍ទី១៖ ការចូលរួមរបស់ប្រជាពលរដ្ឋ | 1.15 | 30.80 | 39.63 | 23.97 | 4.45 | 3.00 |
| គោលការណ៍ទី២៖ នីតិរដ្ឋ នៅក្នុងឃុំសង្កាត់ | 5.29 | 24.42 | 35.03 | 27.53 | 7.73 | 3.08 |
| គោលការណ៍ទី៣៖ តម្លាភាព | 3.23 | 20.61 | 36.39 | 30.14 | 9.63 | 3.22 |
| គោលការណ៍ទី៤៖ ការព្រមព្រៀងឯកភាពគ្នា | 0.00 | 26.24 | 37.53 | 26.24 | 10.00 | 3.20 |
| គោលការណ៍ទី៥៖ សមធម៌ | 3.19 | 28.02 | 22.63 | 35.44 | 10.72 | 3.22 |
| គោលការណ៍ទី៦៖ ប្រសិទ្ធភាពខ្ពស់ | 1.19 | 37.87 | 32.93 | 23.87 | 4.14 | 2.92 |
| គោលការណ៍ទី៧៖ គណនេយ្យភាព | 3.33 | 43.33 | 16.67 | 33.33 | 3.33 | 2.90 |
| គោលការណ៍ទី៨៖ ការឆ្លើយតប | 6.67 | 23.33 | 33.33 | 26.67 | 10.00 | 3.10 |
| លទ្ធផលមធ្យមទាំង០៨គោលការណ៍ | 3.01 | 29.33 | 31.77 | 28.40 | 7.50 | 3.08 |

- លទ្ធផលវាយតម្លៃនៅ ឃុំសំរោងក្រោម ស្រុកបន្ទាយមាស ខេត្តកំពត

| | ចំនួននៃអ្នកចូលរួមផ្តល់ពិន្ទុ និងផ្តល់ចម្លើយ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ភេទ | | អាយុ | | កម្រិតវប្បធម៌ | | ក្រុមប្រឹក្សាឃុំ/សង្កាត់ជា......... | | ក្រុមប្រឹក្សាឃុំ/សង្កាត់មានតួនាទីជា........ (អ្នកចូលរួមជ្រើសរើសចម្លើយច្រើន) | |
| ខេត្តកំពត | ប្រុស | 9 | ១៨-៣០ | 8 | 1.បឋមសិក្សា | 7 | ១. ជាមន្ត្រីរាជការ | 0 | ១. ធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ | 12 |
| | ស្រី | 15 | ៣១-៤៥ | 9 | 2.មធ្យមសិក្សាកំរិត១ | 9 | ២. ជាអ្នកមានលុយ | 0 | ២. លើកទឹកចិត្ត ឱ្យមានការបង្កើនផាសុខភាព និងសុខមាលភាពរបស់ប្រជាពលរដ | 11 |
| | មិនផ្តល់ចម្លើយ | 0 | ៤៦-៦០ | 5 | 3.មធ្យមសិក្សាកំរិត២ | 5 | ៣. មិនដឹង | 1 | ៣. អ្នកការពារ ថែរក្សាបរិស្ថាន និងធនធានធម្មជាត | 9 |
| | | | ៦០ ឡើង | 1 | 4.ឧត្តមសិក្សា | 3 | ៤. ជាអ្នក ជាប់ឆ្នោត ត្រូវបាន | 23 | ៤. បំពេញកិច្ចការជាទូទៅឆ្លើយតបតម្រូវការ របស់ប្រជាពលរដ | 20 |
| | | | មិនផ្តល់ចម្លើយ | 1 | 5.អនុបណ្ឌិត | 0 | ៥. ជាស្មៀនឃុំសង្កាត់ | 0 | ៥. អនុវត្តកិច្ចការអត្រានុកូលដ្ឋាន និង កិច្ចការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះអ្នកបោះឆ្នោត | 21 |
| | | | | | ផ្សេងទៀត | 0 | ៦. ជាមន្ត្រីប៉ូលីស ទាហាន | 0 | ៦. ចាត់ចែងសេវាសាធារណៈមូលដ្ឋាន | 10 |
| | | | | | មិនផ្តល់ចម្លើយ | 0 | មិនជ្រើសរើសចម្លើយ | 0 | ៧. ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងលើកកំពស់ជីវភាពរស់នៅរបស់អ្នកភូម | 17 |
| | | | | | | | | | ៨. សំរបសំរួលទស្សនៈរបស់ប្រជាពលរដ្ឋឲ្យមានការឃោគយល់គ្នាទៅវិញទៅមក | 16 |
| | | | | | | | | | ៩. អនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន | 13 |

| ការអនុវត្តគោលកាណ៍ | មិនពេញចិត្ត(%) | ពេញចិត្តខ្លះ(%) | ពេញចិត្តមធ្យម(%) | ពេញចិត្តច្រើន (%) | ពេញចិត្តទាំងស្រុង (%) | ពិន្ទុមធ្យម នៃ(#/5) |
|---|---|---|---|---|---|---|
| គោលការណ៍ទី១៖ ការចូលរួមរបស់ប្រជាពលរដ្ឋ | 2.84 | 9.90 | 18.24 | 44.99 | 24.03 | 3.77 |
| គោលការណ៍ទី២៖ នីតិរដ្ឋ នៅក្នុងឃុំសង្កាត់ | 4.26 | 5.39 | 24.37 | 41.49 | 24.50 | 3.77 |
| គោលការណ៍ទី៣៖ តម្លាភាព | 4.26 | 10.51 | 25.36 | 36.32 | 23.55 | 3.64 |
| គោលការណ៍ទី៤៖ ការព្រមព្រៀងឯកភាពគ្នា | 4.17 | 2.08 | 29.17 | 41.67 | 22.92 | 3.77 |
| គោលការណ៍ទី៥៖ សមធម៌ | 4.35 | 4.35 | 28.99 | 42.03 | 20.29 | 3.70 |
| គោលការណ៍ទី៦៖ ប្រសិទ្ធភាពខ្ពស់ | 4.23 | 4.26 | 34.57 | 35.14 | 21.80 | 3.66 |
| គោលការណ៍ទី៧៖ គណនេយ្យភាព | 9.09 | 9.09 | 18.18 | 40.91 | 22.73 | 3.59 |
| គោលការណ៍ទី៨៖ ការឆ្លើយតប | 4.76 | 9.52 | 9.52 | 33.33 | 42.86 | 4.00 |
| លទ្ធផលមធ្យមទាំង០៨គោលការណ៍ | 4.74 | 6.89 | 23.55 | 39.48 | 25.33 | 3.74 |

- លទ្ធផលវាយតម្លៃនៅ ឃុំតាផូ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ

| | ចំនួននៃអ្នកចូលរួមផ្តល់ពិន្ទុ និងផ្តល់ចម្លើយ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ភេទ | | អាយុ | | កម្រិតវប្បធម៌ | | ក្រុមប្រឹក្សាឃុំ/សង្កាត់ជា......... | | ក្រុមប្រឹក្សាឃុំ/សង្កាត់ មាន តួនាទី ជា........ (អ្នកចូលរួមជ្រើសរើសចម្លើយច្រើន) | |
| ខេត្តបន្ទាយមានជ័យ | ប្រុស | 13 | ១៨-៣០ | 10 | 1.បឋមសិក្សា | 6 | ១. ជាមន្ត្រីរាជការ | 0 | ១. ធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ | 10 |
| | ស្រី | 15 | ៣១-៤៥ | 6 | 2.មធ្យមសិក្សាកំរិត១ | 14 | ២. ជាអ្នកមានលុយ | 1 | ២. លើកទឹកចិត្ត ឱ្យមានការបង្កើនផាសុខភាព និងសុខមាលភាពរបស់ប្រជាពលរដ | 16 |
| | មិនផ្តល់ចម្លើយ | 0 | ៤៦-៦០ | 8 | 3.មធ្យមសិក្សាកំរិត២ | 3 | ៣. មិនដឹង | 0 | ៣. អ្នកការពារ ថែរក្សាបរិស្ថាន និងធនធានធម្មជាត | 14 |
| | | | ៦០ ឡើង | 1 | 4.ឧត្តមសិក្សា | 1 | ៤. ជាអ្នក ជាប់ឆ្នោត ត្រូវបាន | 25 | ៤. បំពេញកិច្ចការជាទូទៅឆ្លើយតបតម្រូវការ របស់ប្រជាពលរដ | 21 |
| | | | មិនផ្តល់ចម្លើយ | 3 | 5.អនុបណ្ឌិត | 0 | ៥. ជាស្មៀនឃុំសង្កាត់ | 2 | ៥. អនុវត្តកិច្ចការអត្រានុកូលដ្ឋាន និង កិច្ចការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះអ្នកបោះឆ្នោត | 17 |
| | | | | | ផ្សេងទៀត | 0 | ៦. ជាមន្ត្រីប៉ូលីស ទាហាន | 0 | ៦. ចាត់ចែងសេវាសាធារណៈមូលដ្ឋាន | 14 |
| | | | | | មិនផ្តល់ចម្លើយ | 4 | មិនជ្រើសរើសចម្លើយ | 0 | ៧. ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងលើកកំពស់ជីវភាពរស់នៅរបស់អ្នកភូម | 19 |
| | | | | | | | | | ៨. សំរបសំរួលទស្សនៈរបស់ប្រជាពលរដ្ឋឲ្យមានការឃោគយល់គ្នាទៅវិញទៅមក | 18 |
| | | | | | | | | | ៩. អនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន | 13 |

| ការអនុវត្តគោលកាណ៍ | មិនពេញចិត្ត(%) | ពេញចិត្តខ្លះ(%) | ពេញចិត្តមធ្យម(%) | ពេញចិត្តច្រើន (%) | ពេញចិត្តទាំងស្រុង (%) | ពិន្ទុមធ្យម នៃ(#/5) |
|---|---|---|---|---|---|---|
| គោលការណ៍ទី១៖ ការចូលរួមរបស់ប្រជាពលរដ្ឋ | 6.67 | 12.23 | 9.29 | 33.30 | 38.50 | 3.85 |
| គោលការណ៍ទី២៖ នីតិរដ្ឋ នៅក្នុងឃុំសង្កាត់ | 2.05 | 13.56 | 14.90 | 26.96 | 42.53 | 3.94 |
| គោលការណ៍ទី៣៖ តម្លាភាព | 3.92 | 0.00 | 33.23 | 27.31 | 35.54 | 3.91 |

| | | | | | | |
|---|---|---|---|---|---|---|
| គោលការណ៍ទី៤៖ ការព្រមព្រៀងឯកភាពគ្នា | 2.00 | 8.00 | 18.00 | 44.00 | 28.00 | 3.88 |
| គោលការណ៍ទី៥៖ សមធម៌ | 1.28 | 5.28 | 14.51 | 43.44 | 35.49 | 4.07 |
| គោលការណ៍ទី៦៖ ប្រសិទ្ធភាពខ្ពស់ | 3.28 | 7.99 | 24.67 | 31.72 | 32.34 | 3.82 |
| គោលការណ៍ទី៧៖ គណនេយ្យភាព | 3.70 | 3.70 | 18.52 | 37.04 | 37.04 | 4.00 |
| គោលការណ៍ទី៨៖ ការឆ្លើយតប | 3.85 | 3.85 | 11.54 | 19.23 | 61.54 | 4.31 |
| លទ្ធផលមធ្យមទាំង០៨គោលការណ៍ | 3.34 | 6.83 | 18.08 | 32.87 | 38.87 | 3.97 |

- លទ្ធផលវាយតម្លៃនៅ សង្កាត់បារាយណ៍ ក្រុងព្រៃវែង ខេត្តព្រៃវែង

| | ចំនួននៃអ្នកចូលរួមផ្តល់ពិន្ទុ និងផ្តល់ចម្លើយ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ភេទ | | អាយុ | | កម្រិតវប្បធម៌ | | ក្រុមប្រឹក្សាឃុំ/សង្កាត់ជា......... | | ក្រុមប្រឹក្សាឃុំ/សង្កាត់មានតួនាទីជា........ (អ្នកចូលរួមជ្រើសរើសចម្លើយច្រើន) | |
| ខេត្តព្រៃវែង | ប្រុស | 14 | ១៨-៣០ | 4 | 1.បឋមសិក្សា | 14 | ១. ជាមន្ត្រីរាជការ | 1 | ១. ធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ | 18 |
| | ស្រី | 9 | ៣១-៤៥ | 6 | 2.មធ្យមសិក្សាកំរិត១ | 5 | ២. ជាអ្នកមានលុយ | 0 | ២. លើកទឹកចិត្ត ឱ្យមានការបង្កើនផាសុខភាព និងសុខមាលភាពរបស់ប្រជាពលរដ | 17 |
| | មិនផ្តល់ចម្លើយ | 2 | ៤៦-៦០ | 7 | 3.មធ្យមសិក្សាកំរិត២ | 5 | ៣. មិនដឹង | 0 | ៣. អ្នកការពារ ថែរក្សាបរិស្ថាន និងធនធានធម្មជាត | 18 |
| | | | ៦០ ឡើង | 8 | 4.ឧត្តមសិក្សា | 1 | ៤. ជាអ្នក ជាប់ឆ្នោត ត្រូវបាន | 23 | ៤. បំពេញកិច្ចការជាទូទៅឆ្លើយតបតម្រូវការ របស់ប្រជាពលរដ | 23 |
| | | | មិនផ្តល់ចម្លើប | 0 | 5.អនុបណ្ឌិត | 0 | ៥. ជាស្មៀនឃុំសង្កាត់ | 0 | ៥. អនុវត្តកិច្ចការអត្រានុកូលដ្ឋាន និង កិច្ចការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះអ្នកបោះឆ្នោត | 22 |
| | | | | | ផ្សេងទៀត | 0 | ៦. ជាមន្ត្រីប៉ូលីស ទាហាន | 0 | ៦. ចាត់ចែងសេវាសាធារណៈមូលដ្ឋាន | 21 |
| | | | | | មិនផ្តល់ចម្លើយ | 0 | មិនជ្រើសរើសចម្លើយ | 1 | ៧. ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងលើកកំពស់ជីវភាពរស់នៅរបស់អ្នកភូម | 22 |
| | | | | | | | | | ៨. សំរបសំរួលទស្សនៈរបស់ប្រជាពលរដ្ឋឲ្យមានការយោគយល់គ្នាទៅវិញទៅមក | 21 |
| | | | | | | | | | ៩. អនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន | 19 |

| **ការអនុវត្តគោលកាណ៍** | មិនពេញចិត្ត(%) | ពេញចិត្តខ្លះ(%) | ពេញចិត្តមធ្យម(%) | ពេញចិត្តច្រើន (%) | ពេញចិត្តទាំងស្រុង (%) | ពិន្ទុមធ្យម នៃ(#/5) |
|---|---|---|---|---|---|---|
| គោលការណ៍ទី១៖ ការចូលរួមរបស់ប្រជាពលរដ្ឋ | 0.00 | 1.33 | 13.33 | 34.67 | 50.67 | 4.35 |
| គោលការណ៍ទី២៖ នីតិរដ្ឋ នៅក្នុងឃុំសង្កាត់ | 1.04 | 2.00 | 4.04 | 38.42 | 54.50 | 4.43 |
| គោលការណ៍ទី៣៖ តម្លាភាព | 4.17 | 0.00 | 16.67 | 33.33 | 45.83 | 4.17 |
| គោលការណ៍ទី៤៖ ការព្រមព្រៀងឯកភាពគ្នា | 6.00 | 0.00 | 16.00 | 52.00 | 26.00 | 3.92 |
| គោលការណ៍ទី៥៖ សមធម៌ | 0.00 | 1.33 | 28.00 | 34.67 | 36.00 | 4.05 |
| គោលការណ៍ទី៦៖ ប្រសិទ្ធភាពខ្ពស់ | 2.03 | 4.03 | 21.47 | 35.50 | 36.97 | 4.01 |
| គោលការណ៍ទី៧៖ គណនេយ្យភាព | 0.00 | 0.00 | 32.00 | 32.00 | 36.00 | 4.04 |
| គោលការណ៍ទី៨៖ ការឆ្លើយតប | 0.00 | 0.00 | 20.00 | 24.00 | 56.00 | 4.36 |
| លទ្ធផលមធ្យមទាំង០៨គោលការណ៍ | 1.65 | 1.09 | 18.94 | 35.57 | 42.75 | 4.17 |

- លទ្ធផលវាយតម្លៃនៅ ឃុំសំរោងយា ស្រុកពួក ខេត្តសៀមរាប

| | ចំនួននៃអ្នកចូលរួមផ្តល់ពិន្ទុ និងផ្តល់ចម្លើយ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ភេទ | | អាយុ | | កម្រិតវប្បធម៌ | | ក្រុមប្រឹក្សាឃុំ/សង្កាត់ជា......... | | ក្រុមប្រឹក្សាឃុំ/សង្កាត់មានតួនាទីជា........ (អ្នកចូលរួមជ្រើសរើសចម្លើយច្រើន) | |
| ខេត្តសៀមរាប | ប្រុស | 15 | ១៨-៣០ | 9 | 1.បឋមសិក្សា | 10 | ១. ជាមន្ត្រីរាជការ | 0 | ១. ធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ | 20 |
| | ស្រី | 15 | ៣១-៤៥ | 5 | 2.មធ្យមសិក្សាកំរិត១ | 8 | ២. ជាអ្នកមានលុយ | 0 | ២. លើកទឹកចិត្ត ឱ្យមានការបង្កើនផាសុខភាព និងសុខមាលភាពរបស់ប្រជាពលរដ | 22 |
| | មិនផ្តល់ចម្លើយ | 1 | ៤៦-៦០ | 14 | 3.មធ្យមសិក្សាកំរិត២ | 8 | ៣. មិនដឹង | 0 | ៣. អ្នកការពារ ថែរក្សាបរិស្ថាន និងធនធានធម្មជាត | 11 |
| | | | ៦០ ឡើង | 3 | 4.ឧត្តមសិក្សា | 4 | ៤. ជាអ្នក ជាប់ឆ្នោត ត្រូវបាន | 31 | ៤. បំពេញកិច្ចការជាទូទៅឆ្លើយតបតម្រូវការ របស់ប្រជាពលរដ | 26 |
| | | | មិនផ្តល់ចម្លើយ | 0 | 5.អនុបណ្ឌិត | 0 | ៥. ជាស្មៀនឃុំសង្កាត់ | 0 | ៥. អនុវត្តកិច្ចការអត្រានុកូលដ្ឋាន និង កិច្ចការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះអ្នកបោះឆ្នោត | 23 |
| | | | | | ផ្សេងទៀត | 1 | ៦. ជាមន្ត្រីប៉ូលីស ទាហាន | 0 | ៦. ចាត់ចែងសេវាសាធារណៈមូលដ្ឋាន | 19 |
| | | | | | មិនផ្តល់ចម្លើយ | 0 | មិនជ្រើសរើសចម្លើយ | 0 | ៧. ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងលើកកំពស់ជីវភាពរស់នៅរបស់អ្នកភូម | 22 |
| | | | | | | | | | ៨. សំរបសំរួលទស្សនៈរបស់ប្រជាពលរដ្ឋឲ្យមានការឃោគយល់គ្នាទៅវិញទៅមក | 20 |
| | | | | | | | | | ៩. អនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន | 17 |

| ការអនុវត្តគោលកាណ៍ | មិនពេញចិត្ត(%) | ពេញចិត្តខ្លះ(%) | ពេញចិត្តមធ្យម(%) | ពេញចិត្តច្រើន (%) | ពេញចិត្តទាំងស្រុង (%) | ពិន្ទុមធ្យម នៃ(#/5) |
|---|---|---|---|---|---|---|
| គោលការណ៍ទី១៖ ការចូលរួមរបស់ប្រជាពលរដ្ឋ | 1.08 | 6.45 | 27.96 | 40.86 | 23.66 | 3.80 |
| គោលការណ៍ទី២៖ នីតិរដ្ឋ នៅក្នុងឃុំសង្កាត់ | 2.59 | 4.95 | 20.66 | 38.04 | 33.76 | 3.95 |
| គោលការណ៍ទី៣៖ តម្លាភាព | 1.67 | 8.33 | 35.00 | 30.00 | 25.00 | 3.68 |
| គោលការណ៍ទី៤៖ ការព្រមព្រៀងឯកភាពគ្នា | 3.33 | 6.67 | 25.00 | 43.33 | 21.67 | 3.73 |
| គោលការណ៍ទី៥៖ សមធម៌ | 2.30 | 3.45 | 29.89 | 35.63 | 28.74 | 3.85 |
| គោលការណ៍ទី៦៖ ប្រសិទ្ធភាពខ្ពស់ | 2.15 | 7.01 | 26.54 | 35.68 | 28.62 | 3.82 |
| គោលការណ៍ទី៧៖ គណនេយ្យភាព | 0.00 | 10.00 | 16.67 | 43.33 | 30.00 | 3.93 |
| គោលការណ៍ទី៨៖ ការឆ្លើយតប | 0.00 | 6.45 | 12.90 | 41.94 | 38.71 | 4.13 |
| លទ្ធផលមធ្យមទាំង០៨គោលការណ៍ | 1.64 | 6.66 | 24.33 | 38.60 | 28.77 | 3.86 |

# បញ្ជីសំណួរសម្រាប់ប្រជាពលរដ្ឋវាយតម្លៃ

ខុមហ្វ្រែល COMFREL

## វេទិកាប្រជាពលរដ្ឋ ស្តីពី
## ការផ្សព្វផ្សាយ និងវាយតម្លៃដំណើរការអភិបាលកិច្ចល្អនៅមូលដ្ឋានឃុំ/សង្កាត់
## បញ្ជីសំណួរវាយតម្លៃ

ព័ត៌មាន អត្តសញ្ញាណ និងលទ្ធផលវាយតម្លៃរបស់លោកអ្នកនឹងរក្សាទុកជាការសម្ងាត់។ សូមឆ្លើយ និងវាយតម្លៃដោយប្រើប្រាស់សញ្ញា ✖ ចំពោះបញ្ជីសំណួរដូចខាងក្រោម៖

❖ **ព័ត៌មានប្រជាសាស្ត្ររបស់អ្នក**

| | | | | | | |
|---|---|---|---|---|---|---|
| **ភេទ** | □ ប្រុស<br>□ ស្រី | **អាយុ** | ១.□ ១៨-៣០<br>២.□ ៣១-៤៥<br>៣.□ ៤៥-៦០<br>៤.□ ៦០ ឡើង | **កម្រិតវប្បធម៌** | ១.□ បឋមសិក្សា<br>៣.□ មធ្យមសិក្សាកំរិត២<br>៥.□ អនុបណ្ឌិត | ២.□ មធ្យមសិក្សាកំរិត១<br>៤.□ ឧត្តមសិក្សា<br>៦.□ ........(សូមបញ្ជាក់) |

❖ **ការយល់ដឹងទូទៅអំពីក្រុមប្រឹក្សាឃុំ/សង្កាត់៖**

| | | | |
|---|---|---|---|
| ១ | តើ ក្រុមប្រឹក្សាឃុំ/សង្កាត់ជានរណា?(ជ្រើសរើសចម្លើយមួយ) | ១.□ | ជាមន្ត្រីរាជការ |
| | | ២.□ | ជាអ្នកមានលុយ |
| | | ៣.□ | មិនដឹង |
| | | ៤.□ | ជាអ្នក ជាប់ឆ្នោត ត្រូវបានជ្រើសរើសដោយប្រជាពលរដ្ឋតាមរយៈការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ |
| | | ៥.□ | ជាស្មៀនឃុំសង្កាត់ |
| | | ៦.□ | ជាមន្ត្រីប៉ូលីស ទាហាន |
| ២ | តើអ្នកដឹងទេថា ក្នុងតួនាទីបំរើការងារមូលដ្ឋាន និងជាភ្នាក់ងារតំណាងរដ្ឋ តើរដ្ឋបាលឃុំសង្កាត់មានតួនាទី និងភារកិច្ចអ្វីខ្លះ? (ចម្លើយមានច្រើន) | ១.□ | ធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ |
| | | ២.□ | លើកទឹកចិត្ត ឱ្យមានការបង្កើនផាសុខភាព និងសុខមាលភាពរបស់ប្រជាពលរដ្ឋ |
| | | ៣.□ | អ្នកការពារ ថែរក្សាបរិស្ថាន និងធនធានធម្មជាតិ |
| | | ៤.□ | បំពេញកិច្ចការជាទូទៅឆ្លើយតបតម្រូវការ របស់ប្រជាពលរដ្ឋ |
| | | ៥.□ | អនុវត្តកិច្ចការអត្រានុកូលដ្ឋាន និង កិច្ចការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះអ្នកបោះឆ្នោត |

| | | | |
|---|---|---|---|
| | | ៦.□ | ចាត់ចែងសេវាសាធារណៈមូលដ្ឋាន |
| | | ៧.□ | ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងលើកកំពស់ជីវភាពរស់នៅរបស់អ្នកភូមិ |
| | | ៨.□ | សំរបសំរួលទស្សនៈរបស់ប្រជាពលរដ្ឋឲ្យមានការយោគយល់គ្នាទៅវិញទៅមក |
| | | ៩.□ | អនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ |
| | | ១០.□ | មិនដឹង |

❖ **ការវាយតម្លៃអំពីការពេញចិត្តលើលទ្ធផលនៃដំណើរការអភិបាលកិច្ចនៅឃុំសង្កាត់៖**

| ល.រ. | គោលការណ៍អភិបាលកិច្ចល្អ នៅក្នុងឃុំ/សង្កាត់ | ការវាយតម្លៃ | | | | | |
|---|---|---|---|---|---|---|---|
| | 1. **ការចូលរួមរបស់ប្រជាពលរដ្ឋ** | មិនពេញចិត្ត 0-២០% (១) | ពេញចិត្តតិចៈ ២១%-៤០% (២) | ពេញចិត្តគួរសម ៤១%-៦០% (៣) | ពេញចិត្តច្រើន ៦១%-៨០% (៤) | ពេញចិត្តទាំងស្រុង ៨១%-១០០% (៥) | មិនអាចវាយតម្លៃ |
| 1 | ការចូលរួមដោយផ្ទាល់របស់ប្រជាពលរដ្ឋក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងអនុវត្តសេចក្តីសម្រេចចិត្ត | | | | | | |
| 2 | ការបង្កើតនីតិវិធីសម្រាប់ឲ្យប្រជាពលរដ្ឋជ្រើសរើសអ្នកតំណាងរបស់ខ្លួនដើម្បីចូលរួមការធ្វើសេចក្តីសម្រេចចិត្ត និងអនុវត្តសេចក្តីសម្រេចចិត្ត | | | | | | |
| 3 | សកម្មភាពលើកទឹកចិត្តឲ្យប្រជាពលរដ្ឋចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងអនុវត្តសេចក្តីសម្រេចចិត្ត | | | | | | |
| | 2. **នីតិរដ្ឋនៅក្នុងឃុំសង្កាត់** | មិនពេញចិត្ត 0-២០% (១) | ពេញចិត្តតិចៈ ២១%-៤០% (២) | ពេញចិត្តគួរសម ៤១%-៦០% (៣) | ពេញចិត្តច្រើន ៦១%-៨០% (៤) | ពេញចិត្តទាំងស្រុង ៨១%-១០០% (៥) | មិនអាចវាយតម្លៃ |
| 4 | មានឯកសារក្របខណ្ឌច្បាប់គ្រប់គ្រាន់ដើម្បីបំរើ និងការពារប្រយោជន៍សាធារណៈ និងប្រជាពលរដ្ឋនៅក្នុងឃុំសង្កាត់ | | | | | | |
| 5 | ការអនុវត្តច្បាប់ដោយមិនលំអៀងនិងដោយស្របតាមគោលការណ៍សិទ្ធិមនុស្ស ជាពិសេសការពារក្រុមជនងាយរងគ្រោះ | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 6 | ការយកចិត្តទុកដាក់ចំពោះសិទ្ធិមនុស្សរួមមានសិទ្ធិចូលរួម និងសិទ្ធិកាន់កាប់ដីធ្លី ឬទ្រព្យសម្បត្តិរបស់ក្រុមជនជាតិដើមភាគតិច ស្ត្រី និងក្រុមងាយរងគ្រោះ | | | | | | |
| 7 | ការដោះស្រាយជម្លោះនៅក្នុងមូលដ្ឋានដោយយុត្តិធម៌ និងដោយមិនលំអៀង | | | | | | |
| | **3. តម្លាភាពនៅក្នុងឃុំសង្កាត់** | មិនពេញចិត្ត 0-២០% (១) | ពេញចិត្តខ្លះ ២១%-៤០% (២) | ពេញចិត្តមធ្យម ៤១%-៦០% (៣) | ពេញចិត្តច្រើន ៦១%-៨០% (៤) | ពេញចិត្តទាំងស្រុង ៨១%-១០០% (៥) | មិនអាចវាយតម្លៃ |
| 8 | ការធ្វើសេចក្តីសម្រេចចិត្ត និងអនុវត្តសេចក្តីសម្រេចចិត្តអនុលោមទៅតាមច្បាប់ និងបទបប្បញ្ញត្តិនានា | | | | | | |
| 9 | ការផ្សព្វផ្សាយជាចំហនូវព័ត៌មានទាក់ទងនឹងសេចក្តីសម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចចិត្ត តាមរយៈមធ្យោបាយ សមស្រប និងអាចស្វែងរកបាន និងងាយល់បាន ជាពិសេសចំពោះអ្នកដែលទទួលរងនូវផលប៉ះពាល់ផ្ទាល់ | | | | | | |
| | **4. ការព្រមព្រៀងឯកភាពគ្នា** | មិនពេញចិត្ត 0-២០% (១) | ពេញចិត្តខ្លះ ២១%-៤០% (២) | ពេញចិត្តមធ្យម ៤១%-៦០% (៣) | ពេញចិត្តច្រើន ៦១%-៨០% (៤) | ពេញចិត្តទាំងស្រុង ៨១%-១០០% (៥) | មិនអាចវាយតម្លៃ |
| 10 | ការឯកភាពគ្នាក្នុងចំណោមក្រុមប្រជាពលរដ្ឋផ្សេងគ្នា និងអាជ្ញាធរឃុំសង្កាត់ក្នុងការកំណត់យក ឬជ្រើសរើសយកគម្រោងអភិវឌ្ឍឃុំសង្កាត់ ឬវិធីសាស្ត្រអនុវត្តន៍ផ្សេងៗ | | | | | | |
| 11 | សកម្មភាពរបស់ឃុំ/សង្កាត់ដើម្បីសម្រុសសម្រួលឲ្យមានការព្រមព្រៀងឯកភាពគ្នា | | | | | | |
| | **5. សមធម៌នៅក្នុងឃុំសង្កាត់** | មិនពេញចិត្ត 0-២០% (១) | ពេញចិត្តខ្លះ ២១%-៤០% (២) | ពេញចិត្តមធ្យម ៤១%-៦០% (៣) | ពេញចិត្តច្រើន ៦១%-៨០% (៤) | ពេញចិត្តទាំងស្រុង ៨១%-១០០% (៥) | មិនអាចវាយតម្លៃ |
| 12 | ការលើកទឹកចិត្តប្រជាពលរដ្ឋងាយរងគ្រោះនៅក្នុងឃុំសង្កាត់ឲ្យពួកគេយល់ថាសមាជិកពិតប្រាកដនៅក្នុងសង្គមនៃឃុំសង្កាត់របស់ពួកគេ/ | | | | | | |
| 13 | ការបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារដែរ ឬទេ និងការទទួលបន្ទុកការងារ | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 14 | ការបង្កើតគណៈកម្មាធិការកសាងផែនការ និងថវិកា និងការចូលរួមពីតំណាងប្រជាពលរដ្ឋក្នុងកិច្ចប្រជុំគណៈកម្មាធិការនេះ | | | | | | |
| | **6. ប្រសិទ្ធភាពខ្ពស់ក្នុងការងារនៅក្នុងឃុំសង្កាត់** | មិនពេញចិត្ត 0-២០% (១) | ពេញចិត្តខ្លះ ២១%-៤០% (២) | ពេញចិត្តមធ្យម ៤១%-៦០% (៣) | ពេញចិត្តច្រើន ៦១%-៨០% (៤) | ពេញចិត្តទាំងស្រុង ៨១%-១០០% (៥) | មិនអាចវាយតម្លៃ |
| 15 | ការប្រើប្រាស់ធនធាន ពេលវេលា សំភារៈ)និងមនុស្សឲ្យអស់លទ្ធភាព( ដើម្បីទទួលបានគុណភាព និងប្រសិទ្ធភាពជាអតិបរមាក្នុងការអនុវត្តការងារ | | | | | | |
| 16 | ការយកចិត្តទុកដាក់ និងអនុវត្តចំពោះសកម្មភាពដែលជាអាទិភាពខ្ពស់នៅមូលដ្ឋានឃុំសង្កាត់ | | | | | | |
| 17 | មានទម្រង់ឯកសារ ឬការសម្រេចផ្សេងៗ នៅពេលប្រជាពលរដ្ឋស្នើសុំសេវា | | | | | | |
| 18 | ការគិតគូរដល់តម្លៃនៃធនធាន និងនិរន្តភាពនៃការប្រើប្រាស់ និងផលប៉ះពាល់ដល់បរិស្ថាន ពេលប្រើប្រាស់ធនធានធម្មជាតិ | | | | | | |
| 19 | ការមិនមានអំពើពុករលួយ នៅក្នុងការអនុវត្តការងាររបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ | | | | | | |
| 20 | ការធ្វើសេចក្ដីសម្រេចដោយផ្អែកលើមតិយោបល់របស់ប្រជាពលរដ្ឋនៅក្នុងឃុំសង្កាត់/ | | | | | | |
| | **7. គណនេយ្យភាពនៅក្នុងឃុំសង្កាត់** | មិនពេញចិត្ត 0-២០% (១) | ពេញចិត្តខ្លះ ២១%-៤០% (២) | ពេញចិត្តមធ្យម ៤១%-៦០% (៣) | ពេញចិត្តច្រើន ៦១%-៨០% (៤) | ពេញចិត្តទាំងស្រុង ៨១%-១០០% (៥) | មិនអាចវាយតម្លៃ |
| 21 | ការអនុវត្តតួនាទី និងភារកិច្ចនៅក្នុងដំណើរការធ្វើសេចក្ដីសម្រេចចិត្ត និងអនុវត្តសេចក្ដីសម្រេចចិត្ត ការទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន ដោយរាយការណ៍ ព្រមទាំងបញ្ជាក់អំពីមូលហេតុ | | | | | | |
| | **8. ការឆ្លើយតបនឹងតម្រូវការនៅក្នុងឃុំសង្កាត់** | មិនពេញចិត្ត 0-២០% (១) | ពេញចិត្តខ្លះ ២១%-៤០% (២) | ពេញចិត្តមធ្យម ៤១%-៦០% (៣) | ពេញចិត្តច្រើន ៦១%-៨០% (៤) | ពេញចិត្តទាំងស្រុង ៨១%-១០០% (៥) | មិនអាចវាយតម្លៃ |
| 22 | ការផ្ដល់សេវា និងបម្រើប្រជាពលរដ្ឋទាំងអស់ឲ្យស្មើភាពគ្នា និងគ្មានការរើសអើងក្នុងពេលវេលាសមស្រប | | | | | | |

# គោលការណ៍ទាំង០៨ នៃអភិបាលកិច្ចល្អមូលដ្ឋាន

**គោលការណ៍អភិបាលកិច្ចល្អនៅមូលដ្ឋានឃុំ/សង្កាត់ចំនួន០៨ចំណុចៈ**

1. **ការចូលរួមរបស់ប្រជាពលរដ្ឋ៖** មានការចូលរួមដោយផ្ទាល់ ឬតាមរយៈអ្នកតំណាង ក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងអនុវត្តសេចក្តីសម្រេចចិត្ត។ ឃុំសង្កាត់ត្រូវអនុវត្តសកម្មភាពរបស់ឃុំ/សង្កាត់ក្នុងការលើកទឹកចិត្តឲ្យប្រជាពលរដ្ឋចូលរួមក្នុងដំណើរការនោះ។
2. **នីតិរដ្ឋ នៅក្នុងឃុំសង្កាត់៖** ឃុំសង្កាត់ត្រូវមាន ឯកសារក្របខណ្ឌច្បាប់គ្រប់គ្រាន់ដើម្បីបំរើ និងការពារប្រយោជន៍សាធារណៈ។ ឃុំ/សង្កាត់ ត្រូវអនុវត្តច្បាប់ដោយមិនលំអៀង និងដោយស្របតាមគោលការណ៍សិទ្ធិមនុស្ស ជាពិសេសការពារក្រុមជនងាយរងគ្រោះ ឬក្រុមភាគតិច។
3. **តម្លាភាព៖** ឃុំ សង្កាត់ធ្វើសេចក្តីសម្រេចចិត្ត និងអនុវត្តសេចក្តីសម្រេចចិត្តអនុលោមទៅតាមច្បាប់ និងបទបប្បញ្ញត្តិនានា។ ហើយពត៌មានទាក់ទងនឹងសេចក្តីសម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចចិត្តត្រូវ បានផ្សព្វផ្សាយជាចំហ តាមរយៈប្រព័ន្ធសមស្រប និងអាចស្វែងរកបាន និងងាយល់បាន ជាពិសេសចំពោះអ្នកដែលទទួលរងនូវផលប៉ះពាល់ផ្ទាល់។
4. **ការព្រមព្រៀងឯកភាពគ្នា៖** ឃុំ/សង្កាត់កំណត់យក ឬជ្រើសរើសយកគម្រោងអភិវឌ្ឍឃុំសង្កាត់ ឬវិធីសាស្ត្រអនុវត្តន៍ផ្សេងៗដោយទទួលបានការឯកភាពគ្នាក្នុងចំណោមក្រុមប្រជាពលរដ្ឋផ្សេងគ្នា(សំដៅដល់ក្រុមប្រជាពលរដ្ឋមានជំនឿ សាសនាខុសគ្នាជាដើម)។
5. **សមធម៌៖** ប្រជាពលរដ្ឋងាយរងគ្រោះនៅក្នុងឃុំសង្កាត់ត្រូវបានលើកទឹកចិត្តឲ្យ និងទទួលបានបរិយាកាសដែលពួកគេយល់ថាចូលរួមជាសមាជិកពិតប្រាកដនៅក្នុងសង្គមនៃឃុំ/សង្កាត់របស់ពួកគេ។ ឃុំ/សង្កាត់មានគណៈកម្មធិការទទួលបន្ទុកកិច្ចការនារី និងកុមារ និងមានមន្ត្រីទទួលបន្ទុកការងារនេះឲ្យបានច្បាស់លាស់។ ឃុំ/សង្កាត់មានគណៈកម្មធិការកសាងផែនការ និងថវិកា និងមានតំណាងប្រជាពលរដ្ឋបានចូលរួមប្រជុំគណៈកម្មាធិការនេះ។
6. **ប្រសិទ្ធភាពខ្ពស់៖** ឃុំ/សង្កាត់ប្រើប្រាស់ធនធាន (ពេលវេលា សំភារៈ និងមនុស្ស)ឲ្យអស់លទ្ធភាពដើម្បីទទួលបានគុណភាព និងប្រសិទ្ធភាពជាអតិបរមា និងយកចិត្តទុកដាក់ និងអនុវត្តចំពោះសកម្មភាពដែលជាអាទិភាពខ្ពស់ ដោយគិតដល់តម្លៃនៃធនធាន និងនិរន្តភាពនៃការប្រើប្រាស់ និងផលប៉ះពាល់ដល់បរិស្ថាន។ ឃុំ/សង្កាត់មិនត្រូវផ្តល់ការលំបាកទាក់ទងនឹងទម្រង់ឯកសារ ឬការសម្រេចផ្សេងៗ នៅពេលប្រជាពលរដ្ឋស្នើសុំសេវា។ ការអនុវត្តការងាររបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ ត្រូវតែមិនមានអំពើពុករលួយ ហើយធ្វើសេចក្តីសម្រេចដោយផ្អែកលើមតិយោបល់របស់ប្រជាពលរដ្ឋនៅក្នុងឃុំ/សង្កាត់។
7. **គណនេយ្យភាព៖** ក្រុមប្រឹក្សាឃុំ/សង្កាត់អនុវត្តតួនាទី និងភារកិច្ចនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងអនុវត្តសេចក្តីសម្រេចចិត្ត ទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន ដោយរាយការណ៍ ព្រមទាំងបញ្ជាក់អំពីមូលហេតុឲ្យបានច្បាស់លាស់។
8. **ការឆ្លើយតប៖** ឃុំ/សង្កាត់ប្រឹងប្រែងផ្តល់សេវា និងបម្រើប្រជាពលរដ្ឋទាំងអស់ឲ្យស្មើភាពគ្នា គ្មានការរើសអើងក្នុងពេលវេលាសមស្រប។ សម្រេចដោយផ្អែកលើមតិយោបល់របស់ប្រជាពលរដ្ឋនៅក្នុងឃុំ/សង្កាត់។

ឯកសារយោង៖ អភិបាលកិច្ចល្អសម្រាប់ក្រុមប្រឹក្សាឃុំ/សង្កាត់ ដោយនាយដ្ឋានរដ្ឋបាលមូលដ្ឋាន នៃក្រសួងមហាផ្ទៃ ឆ្នាំ២០០៥

# រូបភាពសកម្មភាពវេទិកាប្រជាពលរដ្ឋនៅឃុំ/សង្កាត់



